គណៈកម្មាធិការ បំបាត់ពេស្យាចារ ការរំលោភ និងជួញដូរកុមារ នៅកម្ពុជា

(អុិកផាត កម្ពុជា)

សហការជាមួយ

# រាយការណ៍

## គម្រោង ស្ថិតិរួមរបស់អង្គការនានា ស្តីអំពីការរំលោភសេពសន្ថវៈ និង ជួញដូរ

## ឆ្នាំ ២០០៣-២០០៤

ឧបត្ថម្ភដោយៈ

## មាតិកា

**បញ្ជីអក្សរកាត់........................................................................................៤**

**ខ្លឹមសារសង្ខេប........................................................................................៥**

**I. សេចក្តីផ្តើម........................................................................................៩**

វិធីសាស្ត្រ........................................................................................១០

ដែនកំណត់នៃការសិក្សា........................................................................................១២

**II. ស្ថានភាពទូទៅ........................................................................................១២**

ការរំលោភសេពសន្ថវៈ........................................................................................១៤

ការជួញដូរ........................................................................................១៧

**III. ការបង្ហាញទិន្នន័យ........................................................................................២០**

ការរំលោភសេពសន្ថវៈ........................................................................................២០

ការជួញដូរ........................................................................................២៩

ជនរងគ្រោះ........................................................................................៣៤

**IV. អនុសាសន៍........................................................................................៣៧**

**V. ភាពខ្វះខាតនៃទិន្នន័យ........................................................................................៣៩**

**ឯកសារយោង........................................................................................៤១**

## បញ្ជីតារាង

តារាង ១. រចនាសម្ព័ន្ធនៃប្រជាជនកម្ពុជា ឆ្នាំ ២០០៤........................................................................................១២

តារាង ២. កុមារា កុមារីក្នុងការងារ ឆ្នាំ ២០០៤........................................................................................១៤

តារាង ៣. ចំនួននៃជនល្មើស........................................................................................២៣

តារាង ៤. ការខ្វះខាតរវាងឧក្រិដ្ឋកម្ម និង ការរាយការណ៍ទៅអង្គការ........................................................................................២៤

តារាង ៥. ជនល្មើសដែលត្រូវបានចាប់ខ្លួន........................................................................................២៤

តារាង ៦. ជនល្មើសដែលត្រូវបានកាត់ទោស........................................................................................២៤

តារាង ៧. ភេទនៃជនរងគ្រោះដោយការរំលោភសេពសន្ថវៈ........................................................................................២៥

តារាង ៨. សញ្ជាតិនៃជនរងគ្រោះដោយការរំលោភសេពសន្ថវៈ........................................................................................២៥

តារាង ៩. អាយុនៃជនរងគ្រោះដោយការរំលោភសេពសន្ថវៈ........................................................................................២៦

តារាង ១០. ស្ថានភាពគ្រួសារនៃជនរងគ្រោះដោយការរំលោភសេពសន្ថវៈ........................................................................................២៦

តារាង ១១. កម្រិតវប្បធម៌របស់ជនរងគ្រោះដោយការរំលោភសេពសន្ថវៈ........................................................................................២៦

តារាង ១២. ភេទនៃជនល្មើសប្រព្រឹត្តបទរំលោភសេពសន្ថវៈ........................................................................................២៧

តារាង ១៣. សញ្ជាតិនៃជនល្មើសប្រព្រឹត្តបទរំលោភសេពសន្ថវៈ..........២៧
តារាង ១៤. អាយុនៃជនល្មើសប្រព្រឹត្តបទរំលោភសេពសន្ថវៈ..........២៧
តារាង ១៥. ទំនាក់ទំនងជនល្មើស និង ជនរងគ្រោះ..........២៨
តារាង ១៦. មុខរបររបស់ជនល្មើសប្រព្រឹត្តបទរំលោភសេពសន្ថវៈ..........២៨
តារាង ១៧. ប្រភេទនៃបទចោទប្រកាន់..........៣៣
តារាង ១៨. សញ្ជាតិនៃជនរងគ្រោះដោយការជួញដូរ..........៣៤
តារាង ១៩. ភេទនៃជនរងគ្រោះដោយការជួញដូរ..........៣៥
តារាង ២០. អាយុនៃជនរងគ្រោះដោយការជួញដូរ(ការចាប់ផ្តើម)..........៣៥
តារាង ២១. ស្ថានភាពគ្រួសារនៃជនរងគ្រោះដោយការជួញដូរ..........៣៦
តារាង ២២. ភេទនៃអ្នកជួញដូរ..........៣៦
តារាង ២៣. មុខរបរនៃអ្នកជួញដូរ..........៣៦
តារាង ២៤. ទំនាក់ទំនងជាមួយជនរងគ្រោះ..........៣៧

## តារាងតួលេខ

តួលេខ ១. រចនាសម្ព័ន្ធនៃប្រជាជនកម្ពុជា ឆ្នាំ ២០០៤..........១៣
តួលេខ ២. ករណីរំលោភសេពសន្ថវៈដែលបានផ្តល់ក្នុងកំឡុងពេល..........២០
តរលេខ ៣. ករណីរំលោភសេពសន្ថវៈ តាមខេត្ត ឆ្នាំ ២០០៤..........២១
តួលេខ ៤. ករណីរំលោភសេពសន្ថវៈ តាមខេត្ត ឆ្នាំ ២០០៣..........២១
តួលេខ ៥. ករណីរំលោភតាមខេត្តនីមួយៗ ២០០៣-២០០៤, ១១ ខេត្ត (ផ្នែកទី១)..........២២
តួលេខ ៦. ករណីរំលោភសេពសន្ថវៈ តាមខេត្តនីមួយៗ ២០០៣-២០០៤, ១០ ខេត្ត (ផ្នែកទី២)..........២២
តួលេខ ៧. ករណីជួញដូរដែលបានផ្តល់ក្នុងកំឡុងពេល..........២៩
តួលេខ ៨. ករណីជួញដូរតាមខេត្ត ឆ្នាំ ២០០៤..........៣០
តួលេខ ៩. ករណីជួញដូរតាមខេត្ត ឆ្នាំ ២០០៣..........៣០
តួលេខ ១០. ករណីជួញដូរតាមខេត្តនីមួយៗ ២០០៣-២០០៤, ១០ ខេត្ត (ផ្នែកទី១)..........៣១
តួលេខ ១១. ករណីជួញដូរតាមខេត្តនីមួយៗ ២០០៣-២០០៤, ៩ ខេត្ត (ផ្នែកទី២)..........៣១
តួលេខ ១២. គោលដៅនៃការជួញដូរតាមប្រទេស ឆ្នាំ ២០០៣..........៣២
តួលេខ ១៣. គោលដៅនៃការជួញដូរតាមប្រទេស ឆ្នាំ ២០០៤..........៣២
តួលេខ ១៤. គោលដៅនៃការជួញដូរតាមខេត្ត ឆ្នាំ ២០០៣..........៣៣
តួលេខ ១៥. គោលដៅនៃការជួញដូរតាមខេត្ត ឆ្នាំ ២០០៤..........៣៣
តួលេខ ១៦. ប្រទេសកំណើតនៃជនរងគ្រោះដោយការជួញដូរ..........៣៤

តួលេខ ១៧. ខេត្តកំណើតនៃជនរងគ្រោះដោយការជួញដូរ..........................................................................៣៥

## បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ ១. លក្ខខណ្ឌយោង..................................................................................................................៤៣
ឧបសម្ព័ន្ធ ២. ព័ត៌មានសង្ខេបរបស់បណ្តាអង្គការដែលបានចូលរួម..............................................................៤៥
ឧបសម្ព័ន្ធ ៣. សមាជិក អ៊ិកផាត ត្រឹមខែធ្នូ ២០០៦..................................................................................៤៩
ឧបសម្ព័ន្ធ ៤. សមាជិកគណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ.......................................៥២
ឧបសម្ព័ន្ធ ៥. បញ្ជីសំណួរប្រព័ន្ធទិន្នន័យ...................................................................................................៦៤

## បញ្ជីអក្សរកាត់

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| ADHOC | សមាគមសិទ្ធិមនុស្សកម្ពុជា និង អភិវឌ្ឍន៍ |
| AFESIP | អង្គការសង្គ្រោះ និង ស្តារយុវនីតិសម្បទាយុវនារី |
| APLE | អង្គការសកម្មភាពដើម្បីកុមារ |
| BACK | គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា |
| CCASVA | សមាគមកុមារកម្ពុជាប្រឆាំងទុរភិក្ស និង ហិង្សា |
| CCHDO | អង្គការអភិវឌ្ឍន៍កុមារ និង ជនពិការកម្ពុជា |
| CCPCR | មជ្ឈមណ្ឌលកម្ពុជាដើម្បីការពារសិទ្ធិកុមារ |
| CDP | អង្គការគម្រោងអ្នកការពារច្បាប់កម្ពុជា |
| COC | អង្គការកុមារកម្ពុជា |
| CWCC | មជ្ឈមណ្ឌលកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ |
| CWDA | អង្គការភ្នាក់ងារអភិវឌ្ឍន៍កម្ពុជា |
| DFID/UK | នាយកដ្ឋានសម្រាប់អភិវឌ្ឍន៍អន្តរជាតិ ( រដ្ឋាភិបាលអង់គ្លេស) |
| HCC | អង្គការមជ្ឈមណ្ឌលថែទាំសុខភាពកុមារ |
| Homeland | អង្គការមាតុភូមិកុមារ |
| KMR | អង្គការកុមាររីករាយ |
| KT | អង្គការគ្រួសារថ្មី |
| LAC | អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា |
| LICADHO | សម្ព័ន្ធខ្មែរជំរឿន និង ការពារសិទ្ធិមនុស្ស |
| MoWA | ក្រសួងកិច្ចការនារី |
| NGOCRC | គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ |
| OH | អង្គការផ្ទះយើង |
| PJJ | អង្គការការពារយុត្តិធម៌កុមារ |
| TAF | មូលនិធិអាស៊ី |
| UNDP | កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ |
| UNIFEM | មូលនិធិអង្គការសហប្រជាជាតិដើម្បីស្ត្រី |
| VCAO | អង្គការគាំពារកុមារដែលងាយទទួលរងគ្រោះ |
| WB | ធនាគារពិភពលោក |
| WVC | អង្គការទស្សនៈពិភពលោកកម្ពុជា |

## ខ្លឹមសារសង្ខេប

គណៈកម្មាធិការបំបាត់ពេស្យាចារ ការរំលោភ និងជួញដូរកុមារនៅកម្ពុជា (អ៊ិកផាតកម្ពុជា) ជាបណ្តាញមួយដែលមានអង្គការជាតិនិងអន្តរជាតិចំនួន២៦ ធ្វើការរួមគ្នាដើម្បីធានាថាកុមារ ទាំងអស់នៅក្នុងប្រទេសទទួលបានសិទ្ធិជាមូលដ្ឋានរបស់ពួកគេចាកផុតពីគ្រប់ទម្រង់នៃការរំលោភ និង កេងប្រវ័ញ្ច ផ្លូវភេទ។ អង្គការនេះមានបំណងប្រមូលផ្តុំអ្នកពាក់ព័ន្ធសំខាន់ៗទាំងអស់និងលើកកម្ពស់ការសម្របសម្រួលសកម្មភាពដើម្បីលុបបំបាត់ពេស្យាចារកុមារ រូបភាពអាសអាភាសកុមារ និងការជួញដូរកុមារក្នុងគោលបំណងផ្លូវភេទ។ បេសកកម្មរបស់អង្គការនេះរួមមាន ការលើកកម្ពស់ការយល់ដឹងតស៊ូមតិ ការត្រួតពិនិត្យតាមដាន និងការសម្របសម្រួលសកម្មភាពនិងចែកចាយព័ត៌មានក្នុងចំណោមអ្នកពាក់ព័ន្ធ។ ជាផ្នែកមួយនៃអាណត្តិការងាររបស់ខ្លួន អ៊ិកផាតបាន អនុវត្តគម្រោងមួយហៅថា "ស្ថិតិរួមរបស់អង្គការនានាស្តីពីការរំលោភនិងការជួញដូរ" ដែលទិន្នន័យ និងព័ត៌មាន ដែលបានប្រមូលមកនោះស្តីអំពីការរំលោភ និងជួញដូរ នៃកុមារានិងកុមារីគ្រប់អាយុ និងសញ្ជាតិទាំងអស់នៅក្នុង ប្រទេសកម្ពុជា ពីឆ្នាំ២០០៣ ទៅ ២០០៤។ ច្បាស់ជាងនេះទៀតនោះគឺគោលបំណងរបស់គម្រោងមាន:

១- ដើម្បីផ្តល់នូវការវិភាគស្ថិតិដែលមានសុពលភាពនិងអាចជឿទុកចិត្តបាននៃកំណត់ត្រានៃករណីរំលោភសេពសន្ថវៈ និងជួញដូរ (២០០៣-២០០៤) ដើម្បីបង្កើតព័ត៌មានជាមូលដ្ឋានគ្រឹះទៅដល់អង្គការនានា និង គម្រោងអនាគតរបស់ពួកគេ និង ផ្តល់កំណត់ត្រាត្រឹមត្រូវដើម្បីតាមដានត្រួតពិនិត្យការរីកចម្រើន និង ការផ្លាស់ប្តូរក្នុងរយៈកាលប៉ុន្មានឆ្នាំខាងមុខ

២- ដើម្បីសម្របសម្រួលកំណត់ត្រារបស់អង្គការនានាដើម្បីធានាឱ្យមានការរាយការណ៍ និង ការចែករំលែកព័ត៌មានសំខាន់ៗបានត្រឹមត្រូវ និង ពង្រឹងកិច្ចសហការណ៍ និង ធនធានរបស់អង្គការនានាដែលធ្វើការដើម្បីទប់ស្កាត់ករណីរំលោភសេពសន្ថវៈ និង ជួញដូរ និង ជួយដល់ជនរងគ្រោះ។

គម្រោងនេះត្រូវបានអនុវត្តដោយសហការយ៉ាងជិតស្និទ្ធជាមួយ គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ (NGOCRC) ជាសម្ព័ន្ធមួយដែលមានសមាជិកជា អង្គការ ជាតិ និងអន្តរជាតិចំនួន៤៦។ សម្ព័ន្ធនេះត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៤ ដើម្បីផ្សព្វផ្សាយ តស៊ូមតិ និងតាមដានត្រួត ពិនិត្យលើការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារនៅកម្ពុជា។ កិច្ចខិតខំរួមគ្នាត្រូវបានគ្រប់គ្រង ដោយអនុសារណៈនៃការយោគយល់គ្នាស្តីពីការប្រមូលទិន្នន័យ ការវិភាគ និងការបោះពុម្ពផ្សាយរបាយការណ៍។

អង្គការជាតិ និង អន្តរជាតិចំនួន២២ បានយល់ព្រមចូលរួមក្នុងការសិក្សានេះដោយផ្តល់ជូននូវព័ត៌មានស្តីពីករណី ទាំងឡាយដែលគេបានដោះស្រាយនៅឆ្នាំ២០០៣ និង ឆ្នាំ២០០៤។ ក្នុងនោះអង្គការចំនួន១៣ ជាសមាជិករបស់បណ្តាញអ៊ិកផាត និង NGOCRC ដូចជា AFESIP, BICE, CCASVA, CCPCR, CoC, CPCDO, CWDA, PJJ, VCAO, WVC, Hagar, HCC និង LAC។ អង្គការដទៃទៀត ដែលបានចូលរួមមាន APLE, BACK, CCHDO, CDP, CWCC, Goutte Déau, Homeland, KMR, OH និង KT។ ទិន្នន័យនៅក្នុងរបាយការណ៍នេះមិនតំណាង

ឱ្យប្រទេសកម្ពុជាទាំងមូលនោះទេ ប៉ុន្តែភាគច្រើនឆ្លុះបញ្ចាំងលើ ក្របខណ្ឌនៃការបង្កើតកម្មវិធីរបស់អង្គការដែលចូលរួម ដោយមានរួមបញ្ចូលនូវការកំណត់គោលដៅភូមិសាស្ត្រ និងផ្នែក (ឧ. ស្ត្រី បុរស កុមារី ឬកុមារា) និងសេវាកម្មជាក់លាក់។

គម្រោងនេះប្រើបញ្ជីសំណួរពីរគឺមួយសម្រាប់ការរំលោភសេពសន្ថវៈនិងមួយទៀតសម្រាប់ការជួញដូរដែលត្រូវបាន រៀបចំឡើងដោយផ្អែកលើការពិនិត្យឡើងវិញនូវឧបករណ៍សម្ភាសន៍ផ្សេងៗ របស់អង្គការដែលពាក់ព័ន្ធ។ បញ្ជីសំណួរទាំងនេះត្រូវបានប្រើដោយអង្គការដែលចូលរួមតែ១១ប៉ុណ្ណោះ ដោយសារតែពួកគេមានពេលវេលា និង ធនធានផ្សេងទៀតមិនគ្រប់គ្រាន់។ អង្គការផ្សេងទៀតក្រៅពីនេះប្រើទម្រង់របស់ពួកគេផ្ទាល់ ដែលចម្លើយត្រូវបានបញ្ចូល ក្នុងប្រព័ន្ធទិន្នន័យដោយអ៊ិកផាត។ របាយការណ៍នេះរួមបញ្ចូលទាំងការប្រៀបធៀបព័តិមាន ដែលមានករណីរំលោភសេពសន្ថវៈចំនួន ៥៥៨ ករណី និង ករណីជួញដូរចំនួន ៧៦១ ករណី។

កម្ពុជានៅតែជាប្រទេសមួយក្នុងចំណោមប្រទេសក្រីក្រជាងគេ ទោះជាមានកិច្ចខិតខំប្រឹងប្រែងរបស់ជាតិ អន្តរជាតិ និងផ្នែកផ្សេងៗទៀតក្នុងស្រុក ដើម្បីដោះស្រាយផលប៉ះពាល់នៃសង្គ្រាម និង ភាពក្រីក្រក៏ដោយ។ កុមារដែលជាចំណែកភាគច្រើននៃប្រជាជន ពុំមានសាលាគ្រប់គ្រាន់ និង សេវាកម្ម ជាមូលដ្ឋានផ្សេងៗ ហើយពួកគេត្រូវធ្វើការដើម្បីជួយផ្គត់ផ្គង់គ្រួសារ។ ពួកគេក៏ត្រូវប្រឈមនឹងការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទក្នុងទម្រង់ជាការរំលោភសេពសន្ថវៈ និងជួញដូរផ្លូវភេទ។ កុមារកម្ពុជា ជាពិសេសកុមារីគឺ ជាគោលដៅដែលក្លាយជាជនរង គ្រោះដោយសាការរំលោភនិងជួញដូរ។ ផ្ទុយទៅវិញ កុមារាកំពុងកើនឡើងនូវការពាក់ព័ន្ធជាអ្នករំលោភ។

ការរំលោភសេពសន្ថវៈនិងជួញដូរកើតឡើងស្ទើរតែគ្រប់ទីកន្លែងនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែមានច្រើននៅតាមខេត្តមួយចំនួន ដែលជាកន្លែងប្រមូលផ្តុំភ្ញៀវទេសចរ តំបន់តាមព្រំដែន ឬជាតំបន់ដែលមានការអភិវឌ្ឍន៍ច្រើន និង តំបន់ជាយក្រុង។ មានការកើនឡើងនៃការរាយការណ៍ពិករណីរំលោភសេពសន្ថវៈនិងជួញដូរនៅតាមតំបន់ខ្លះ បើទោះជាមានការថយចុះជារួមពីឆ្នាំ ២០០៣ ដល់២០០៤ ក៏ដោយ។

ការរំលោភសេពសន្ថវៈបានក្លាយជាហិង្សាខ្លាំងឡើងពីឆ្នាំ២០០៣ ដល់២០០៤ ដោយមានការពាក់ព័ន្ធនៃអ្នករំលោភលើសពីម្នាក់ និងការប្រើប្រាស់អាវុធដើម្បីគំរាមជនរងគ្រោះ។ ជនរងគ្រោះតិចតួចណាស់រាយការណ៍ភ្លាមៗ បន្ទាប់ពីបទឧក្រិដ្ឋកើតឡើង ។ ភាគច្រើនគឺរាយករណ៍បន្ទាប់ពីហេតុការណ៍ កន្លងទៅជាច្រើនសប្តាហ៍ និងជាច្រើនខែ។ ស្ថានភាពនេះត្រូវបានរីកចម្រើននៅឆ្នាំ២០០៤ តែទោះជាយ៉ាងណាក៏ដោយ ជនរងគ្រោះមិនមានឆន្ទៈ ក្នុងការរាយការណ៍ជូនប៉ូលិសទេ។ ជនជាប់ចោទភាគច្រើនត្រូវបានចាប់ខ្លួន និង កាត់ទោស។
ខណៈដែលកុមារីកម្ពុជា (សូម្បីតែក្មេងអាយុ១ឆ្នាំ) ត្រូវប៉ះពាល់យ៉ាងខ្លាំងបំផុតដោយការរំលោភ ស្ត្រីវ័យចំណាស់ អ្នកដែលរៀបការហើយ និង ស្ត្រីមេម៉ាយក៏ក្លាយជាគោលដៅនៃការរំលោភដែរ។ ជនរងគ្រោះភាគច្រើនមានកម្រិតវប្បធម៌ត្រឹមបឋមសិក្សាប៉ុណ្ណោះ។

អ្នករំលោភភាគច្រើនជាជនកម្ពុជាភេទប្រុស  រួមទាំងកុមារាផងដែរ ។  ជាញឹកញាប់ពួកគេស្គាល់គ្នាជាមួយជនរងគ្រោះ ដោយសារតែពួកគេជាសមាជិកគ្រួសារ អ្នកជិតខាង ឬ មិត្តភក្តិនឹងគ្នា ។ មានករណីតិចតួច បំផុតដែលប្រព្រឹត្តដោយជនចម្លែកសុទ្ធសាធ ។ មានបុគ្គលិករាជការ និងយោធារបស់រដ្ឋាភិបាលផងដែរ ដែលបានប្រព្រឹត្តបទ រំលោភសេពសន្ថវៈ ។ ហើយមានករណីមួយចំនួនផងដែរដែលប្រព្រឹត្តដោយសិស្ស និស្សិត ។

ទិន្នន័យបានបង្ហាញថាការជួញដូរកើតឡើងភាគច្រើននៅក្នុងស្រុក  ប៉ុន្តែក៏មានករណីឆ្លងដែននិងនៅថ្នាក់តំបន់ផងដែរ ។ ប្រទេសដែលជាគោលដៅភាគច្រើនជាងគេគឺ ប្រទេសថៃ ប៉ុន្តែក៏រួមទាំងប្រទេសម៉ាឡេស៊ី វៀតណាម និង ចិន ផងដែរ ។

ភាគច្រើននៃជនរងគ្រោះដែលត្រូវបានគេជួញដូរ ជាជនជាតិកម្ពុជា ប៉ុន្តែក៏រួមទាំងជនជាតិវៀតណាម ដែលពួកគេមួយចំនួន គឺបានរស់នៅប្រទេសកម្ពុជាយូរមកហើយ ។ ជនជាតិកម្ពុជាដែលត្រូវបានគេជួញដូរច្រើនជាងគេមកពីទីក្រុងភ្នំពេញ អាចជាអ្នកដែលធ្វើចំណាកស្រុក ។ ទាំងបុរស និងស្ត្រីត្រូវបានគេជួញដូរ តែភាគច្រើនជាក្មេងស្រី ។ ទោះជាយ៉ាងណាក៏ដោយ ជនរងគ្រោះរួមមានទាំងអ្នកដែលរៀបការហើយ លែងលះគ្នា ស្ត្រីមេម៉ាយ និង បុរសពោះម៉ាយ ។ ស្ថិតិក៏បានបង្ហាញផង ដែរថាមានការថយចុះនៃចំនួនកុមារ មនុស្សប្រុស ដែលគេជួញដូររវាងឆ្នាំ២០០៣ និង ២០០៤ ។

អ្នកជួញដូរភាគច្រើនក៏ជាស្ត្រីដែលភាគច្រើនជាប់ពាក់ព័ន្ធផ្ទាល់ និង ប្រយោលជាមួយឧស្សាហកម្មផ្លូវភេទ ហើយក៏មានប៉ូលិស និង មន្ត្រីរដ្ឋាភិបាលជាប់ពាក់ព័ន្ធជាអ្នកជួញដូរផងដែរ ។ អ្នកជួញដូរភាគច្រើនមានបណ្តាញនៅក្នុង សហគមន៍ដែលជាប្រភពជាពិសេសជាសាច់ញាតិរបស់ជនរងគ្រោះ ។ ទោះជាយ៉ាងណាក៏ដោយ ឆ្នាំ២០០៤ តួនាទី សមាជិកគ្រួសារដែលជាអ្នកជ្រើសរើសបានថយចុះ រីឯចំនួនអ្នកចម្លែកជាអ្នកជួញដូរបានកើនឡើងទៅវិញ ។

នៅក្នុងបរិបទនៃកិច្ចខិតខំប្រឹងប្រែងជារួមដើម្បីដោះស្រាយភាពក្រីក្រនៅក្នុងប្រទេស មានវិធានការជាក់លាក់ ជាច្រើនត្រូវបានផ្តល់ជាអានុសាសន៍ដើម្បីជួយដោះស្រាយបញ្ហាការរំលោភ និង កេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមរយៈ ការរំលោភ និង ជួញដូរផ្លូវភេទដូចជា :

- អង្គការនានាគួរពិចារណាលើតម្រូវការរបស់កុមារីដែលជាជនរងគ្រោះដោយការរំលោភសេពសន្ថវៈ និង ជួញដូរ និង តម្រូវការរបស់មនុស្សប្រុស និង កុមារា ដែលជាអ្នកប្រព្រឹត្តបទរំលោភ នៅពេលដែលរៀបចំធ្វើគម្រោង ដែលអាចរួមបញ្ចូលទាំងសកម្មភាពលើកកម្ពស់ការយល់ដឹង គម្រោងបណ្តុះបណ្តាល ប្រឹក្សាយោបល់ និង រួមទាំងការជ្រើសរើសបុគ្គលិកសម្រាប់កម្មវិធី ។ល ។
- ជាបន្ថែម ការរកឃើញគួរតែរំលឹកប្រាប់ដល់ស្ថាប័នផ្សេងៗដែលទទួលខុសត្រូវខាងអប់រំ និង បង្កើតតម្លៃ ( គ្រួសារ ប្រព័ន្ធសាលារៀន សហគមន៍សាសនា) កុមារ អំពី( លុបបំបាត់ពាក្យនេះ) សារដែល ជាក់លាក់ និយាយអំពីយ៉េនឌ័រ ដែលមានលក្ខណៈអវិជ្ជមាន និង បំផ្លិចបំផ្លាញ
- ជនល្មើសជាមន្ត្រីរាជការ និងយោធារបស់រដ្ឋាភិបាលគួរតែត្រូវបានផ្តន្ទាទោសធ្ងន់ធ្ងរជាង សំរាប់ការបំពានច្បាប់ និង កិច្ចសន្យាជាមន្ត្រីសាធារណៈ

- ពង្រឹងការចែកចាយព័ត៌មានស្តីអំពីការជួញដូរ ការរំលោភបំពាន និង កេងប្រវ័ញ្ចផ្លូវភេទក្នុងចំណោមអ្នកធ្វើទេសន្តរប្រវេសន៍ និង ក្រុមគ្រួសាររបស់គេនៅក្នុងតំបន់ប្រភព និង គោលដៅដែលបានរកឃើញ
- ពហុបទឧក្រិដ្ឋប្រឆាំងកុមារវ័យក្មេង គួរតែដាក់ទោសអោយធ្ងន់សម្រាប់ជនល្មើស

បន្ថែមទៅលើអនុសាសន៍ខាងលើ ការខ្វះខាតក្នុងការប្រមូលទិន្នន័យក៏ត្រូវបានរកឃើញផងដែរដែលអាចដោះស្រាយបញ្ហាបាននៅពេលអនាគត។

- អ៊ិកផាត NGOCRC និងដៃគូរផ្សេងទៀតនឹងត្រូវតែធ្វើការរួមគ្នាដើម្បីកំណត់អោយបានច្បាស់នូវវិធីសាស្ត្រប្រមូលព័ត៌មានដែលចាំបាច់ឱ្យបានច្រើនតាមដែលអាចធ្វើបាន ដើម្បីឱ្យមានលទ្ធភាពក្នុងការរៀបចំព័ត៌មាន ឱ្យបានត្រឹមត្រូវ និងដើម្បីប្រៀបធៀបនិន្នាការក្នុងរយៈពេលនោះនិងនៅទីកន្លែងផ្សេងៗគ្នា
- មានតម្រូវការ ដើម្បីពិនិត្យបន្តទៅក្នុងលក្ខខណ្ឌជាក់ស្តែងនៅតាមទីកន្លែងដែលមានការរាយការណ៍អំពី ការរំលោភ និងជួញដូរខ្ពស់ដើម្បីជួយពន្យល់ថាតើវារួមចំណែកដល់និន្នាការដែលបានអង្កេតនោះដោយរបៀបណា
- ព័ត៌មានអំពីសេវាកម្មដោយអ្នកផ្តល់ផ្សេងៗគ្នាក៏នឹងត្រូវប្រមូល រៀបចំ និងចែករំលែកដើម្បីជួយកំណត់ ឥទ្ធិពល និងរកមធ្យោបាយដើម្បីសម្របសម្រួលកិច្ចខិតខំប្រឹងប្រែង និង ប្រើប្រាស់ធនធានជាអតិបរមា។ មានតម្រូវការពិសេសក្នុងការរកអោយឃើញ និងកំណត់នូវព័ត៌មានដែលចាំបាច់ និងសំខាន់ៗនៅក្នុងតំបន់នានា អំពីថាតើប្រព័ន្ធយុត្តិធមិ ចាត់ចែងយ៉ាងណាចំពោះការរំលោភ និង ជួញដូរលើកុមារ ផលប៉ះពាល់ផ្លូវចិត្ត និង អារម្មណ៏នៃការរំលោភ និង ជួញដូរ និងថាតើបញ្ហាទាំងនេះត្រូវបានដោះស្រាយដោយរបៀបណា
- តាមដានទៅលើទម្រង់ និងបំណងផ្សេងទៀតរបស់ការជួញដូរដើម្បីកំណត់តម្រូវការរបស់ជនរងគ្រោះ ផ្សេងទៀត ថាតើវាជាប់ទាក់ទងជាមួយការរំលោភ និង ជួញដូរដោយរបៀបណា
- តាមដានត្រួតពិនិត្យលើកិច្ចព្រមព្រៀងដែលមានស្រាប់ទាំងឡាយ ជាមួយប្រទេសថៃ វៀតណាម និង ម៉ាឡេស៊ី ស្តីអំពីការជួញដូរ ដើម្បីមើលលើការអនុវត្ត ភាពគ្រប់គ្រាន់ និងភាពសក្តិសម ក្នុង ការដោះស្រាយបញ្ហានៃការជួញដូរ ហើយដែលលទ្ធផលទាំងនេះគួរតែបញ្ចូលក្នុងការសើរើឡើងវិញ នៃកិច្ចព្រមព្រៀងទាំងនេះ

## សេចក្តីផ្តើម

អ៊ិកផាតកម្ពុជា ជាបណ្តាញមួយដែលមានអង្គការជាតិ និងអន្តរជាតិចំនួន២៦ធ្វើការរួមគ្នាដើម្បីធានាថា កុមារទាំងអស់នៅក្នុងប្រទេសទទួលបាលសិទ្ធិជាមូលដ្ឋានរបស់ពួកគេ ចាកផុតពីគ្រប់ទម្រង់នៃការរំលោភ និងកេង ប្រវ័ញ្ចផ្លូវភេទ[១]។ បណ្តាញនេះត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៥ ដោយអង្គការមួយក្រុម ដែលធ្វើការដើម្បីលុប បំបាត់ការរំលោភ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។ អង្គការនេះមានបំណងប្រមូលផ្តុំ អ្នកពាក់ព័ន្ធសំខាន់ៗ ទាំងអស់និងលើកកម្ពស់ការសម្រប សម្រួលសកម្មភាពដើម្បីលុបបំបាត់ ពេស្យាចារកុមារ រូបភាពអាសអាភាសកុមារ និងការជួញដូរកុមារក្នុងគោលបំណងផ្លូវភេទ។ **ទស្សនៈវិស័យគឺៈ** ការធ្វើឱ្យក្លាយជាការពិតនូវសិទ្ធិរបស់ កុមារគ្រប់រូប ដើម្បីរស់ដោយចាកផុតពី ពេស្យាចារកុមារ ការរំលោភបំពាន រូបភាពអាសអាភាសកុមារ និង ការជួញដូរកុមារដើម្បីគោលបំណងផ្លូវភេទ។ អ៊ិកផាតធ្វើឱ្យក្លាយជាការពិតនូវអ្វីៗទាំងនេះតាមរយៈបេសកកម្ម របស់ខ្លួន គឺការលើកកម្ពស់ការយល់ដឹង ការតស៊ូមតិ ការតាមដានត្រួតពិនិត្យ និងសម្របសម្រួលសកម្មភាពនិងចែករំលែក ព័ត៌មានក្នុងចំណោមអ្នកដែលពាក់ព័ន្ធទាំងឡាយ។ អ៊ិកផាតបានក្លាយជាសមាជិករបស់ អ៊ិកផាតអន្តរជាតិ នៅខែ កញ្ញា ឆ្នាំ២០០២។

ជាផ្នែកមួយនៃបេសកកម្មរបស់ខ្លួនអ៊ិកផាត បានអនុវត្តគម្រោងមួយហៅថា "ស្ថិតិរួមរបស់អង្គការនានាស្តីអំពី ការរំលោភ និង ជួញដូរ" ដែលទិន្នន័យ និង ព័ត៌មានដែលបានប្រមូលមកនោះស្តីអំពីការរំលោភនិងជួញដូរ នៃ កុមារា និងកុមារីគ្រប់អាយុ និងសញ្ជាតិទាំងអស់នៅក្នុងប្រទេសកម្ពុជា ពីឆ្នាំ២០០៣ ទៅ២០០៤។ គម្រោង ត្រូវបានអនុវត្តដើម្បីយល់ឱ្យកាន់តែច្បាស់មូលហេតុដែលជាឫសគល់របស់ការរំលោភ និង ជួញដូរ ចង្វាក់នៃដំណើរការ និងថាមពលនៃការជួញដូរ និងដើម្បីផ្តល់ជាមគ្គុទេសន៍ដល់អង្គការនានាក្នុងការកំណត់តំបន់អាទិភាពដើម្បីឱ្យធនធាន និងជំនួយរបស់ពួកគេត្រូវបានប្រើប្រាស់បានសក្តិសិទ្ធិ និងមានប្រសិទ្ធិភាពខ្ពស់ "គោលបំណងទូទៅរបស់ គម្រោង"។

គោលបំណងជាក់លាក់របស់គម្រោងគឺ :

១- ដើម្បីផ្តល់នូវការវិភាគស្ថិតិដែលមានសុពលភាពនិងដែលអាចជឿទុកចិត្តបាន នៃកំណត់ត្រានៃករណី រំលោភ និងជួញដូរ (២០០៣-២០០៤) ដើម្បីបង្កើតព័ត៌មានជាមូលដ្ឋានគ្រឹះសំខាន់ៗ ទៅដល់អង្គការនានា និងគម្រោងសម្រាប់អនាគតរបស់ពួកគេ និងផ្តល់កំណត់ត្រាត្រឹមត្រូវ ដើម្បីតាមដានត្រួតពិនិត្យការរីកចម្រើន និងការផ្លាស់ប្តូរក្នុងរយៈកាលប៉ុន្មានឆ្នាំខាងមុខ

២- ដើម្បីសម្របសម្រួលកំណត់ត្រារបស់អង្គការនានាដើម្បីធានាឱ្យមានការរាយការណ៍និងចែករំលែកព័ត៌មានសំខាន់ៗបានត្រឹមត្រូវនិងពង្រឹងកិច្ចសហការណ៍និងធនធានរបស់អង្គការដែលធ្វើការដើម្បីទប់ស្កាត់ករណីនៃការរំលោភ និងជួញដូរ និងជួយដល់ជនរងគ្រោះ

[១] មើលឧបសម្ព័ន្ធ ៣

គម្រោងនេះត្រូវបានអនុវត្តដោយមានការសហការជាមួយ NGOCRC ដែលជាសម្ព័ន្ធមួយមានសមាជិកជាអង្គការជាតិ និង អន្តរជាតិចំនួន៤៦។ សម្ព័ន្ធនេះត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៤ ដើម្បីលើកកំពស់ តស៊ូមតិ និង តាមដាន ត្រួតពិនិត្យលើការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារនៅកម្ពុជា។ កិច្ចខិតខំរួមគ្នាត្រូវបានគ្រប់គ្រង ដោយអនុស្សារណៈនៃការយោគយល់គ្នាស្តីពីការប្រមូលទិន្នន័យ ការវិភាគ និងការបោះពុម្ពផ្សាយរបាយការណ៍។

## វិធីសាស្ត្រ

អង្គការជាតិនិងអន្តរជាតិចំនួន២២ ធ្វើការនៅក្នុងវិស័យសិទ្ធិមនុស្សទូទៅ សិទ្ធិកុមារនិងយេនឌ័រ និងអភិវឌ្ឍន៍ នៅតាមតំបន់ផ្សេងៗគ្នានៃប្រទេសបានយល់ព្រមក្លាយជាដៃគូរ ដោយផ្តល់នូវព័ត៌មានអំពីករណីទាំងឡាយដែលពួកគេបានដោះស្រាយក្នុងឆ្នាំ២០០៣ និង ២០០៤។ អង្គការ៩ក្នុងចំណោមអង្គការទាំងនេះ គឺជាសមាជិករបស់បណ្តាញ អ៊ិកផាត ៩ជាសមាជិករបស់បណ្តាញ NGOCRC ហើយដែលអង្គការខ្លះជាសមាជិករបស់បណ្តាញទាំងពីរ។ សមាជិកទាំងអស់គឺ :

| **សមាជិករបស់ អ៊ិកផាត** | **សមាជិករបស់** NGOCRC |
|---|---|
| អង្គការសង្គ្រោះនិងស្តារនីតិសម្បទាយុវនារី (AFESIP) | សមាគមកុមារកម្ពុជាប្រឆាំងទុរភិក្ស និង ហិង្សា (CCASVA) |
| អង្គការកុមារកម្ពុជា (CoC) | អង្គការមជ្ឈមណ្ឌលកម្ពុជាដើម្បីការពារសិទ្ធិកុមារ (CCPCR) |
| អង្គការភ្នាក់ងារអភិវឌ្ឍន៍ស្ត្រីកម្ពុជា (CWDA) | អង្គការគាំពារកុមារដែលងាយទទួលរងគ្រោះ (VCAO) |
| អង្គការគាំពារកុមារដែលងាយទទួលរងគ្រោះ (VCAO) | អង្គការហាកា (Hagar) |
| អង្គការហាការ (Hagar) | អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា (LAC) |
| អង្គការមណ្ឌលថែទាំសុខភាពកុមារ (HCC) | អង្គការគ្រួសារថ្មី (KT) |
| អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា (LAC) | អង្គការការពារយុត្តិធម៌កុមារ (PJJ) |
| អង្គការការពារយុត្តិធម៌កុមារ (PJJ) | អង្គការទស្សនៈពិភពលោក កម្ពុជា (WVC) |
| អង្គការទស្សនៈពិភពលោក កម្ពុជា (WVC) | អង្គការមណ្ឌលថែទាំសុខភាពកុមារ (HCC) |

**អង្គការផ្សេងៗទៀតដែលបានផ្តល់ទិន្នន័យដល់គម្រោង គឺ :**

| | |
|---|---|
| អង្គការសកម្មភាពដើម្បីកុមារ (APLE) | គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា (BAKC) |
| មជ្ឈមណ្ឌលកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ (CWCC) | អង្គការអភិវឌ្ឍន៍កុមារ និង ជនពិការកម្ពុជា (CCHDO) |
| អង្គការផ្ទះយើង (OH) | អង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (CDP) |
| អង្គការកុមាររីករាយ (KMR) | អង្គការដំណក់ទឹក (Goutte d'Eau) |

បណ្តាដៃគូខាងលើបានផ្តល់ស្ថិតិដែលបានមកពីសេវារបស់ពួកគេ ឬ ជាព័ត៌មានអំពីករណីទាំងឡាយដែលពួកគេបានផ្តល់នូវសេវាជាក់លាក់ណាមួយរបស់គេ ឧទាហរណ៍ ការស៊ើបអង្កេត ការសង្គ្រោះ មណ្ឌលស្នាក់នៅ ឬបញ្ជូន ជំនួយផ្នែកច្បាប់ជាដើម សម្រាប់កំឡុងពេល (២០០៣-២០០៤)។ គួរកត់សម្គាល់ផងដែរថា ទិន្នន័យនៅក្នុងរបាយការណ៍នេះមិនតំណាងឱ្យប្រទេសកម្ពុជាទាំងមូលនោះទេ ប៉ុន្តែភាគច្រើនឆ្លុះបញ្ចាំងលើក្របខណ្ឌនៃការបង្កើត កម្មវិធីរបស់អង្គការដែលចូលរួម

ដោយមានរួមបញ្ចូលនូវការកំណត់គោលដៅ ភូមិសាស្ត្រ និងផ្នែក (ឧ. ស្ត្រី បុរស កុមារី ឬកុមារា) និងសេវាកម្មជាក់លាក់ផ្សេងៗ។

គម្រោងប្រព័ន្ធទិន្នន័យប្រើបញ្ជីសំណួរពីរប្រភេទ មួយសម្រាប់ការរំលោភសេពសន្ថវៈ និង មួយសម្រាប់ការជួញដូរ។ បញ្ជីសំណួរសម្រាប់ការរំលោភមានទាំងព័ត៌មានជាមូលដ្ឋានអំពីករណី ការលំអិតអំពីបទឧក្រិដ្ឋ ដូចជាប្រភេទនៃអាវុធ និង ចំនួននៃអ្នកជនល្មើស ព័ត៌មានអំពីជនល្មើស ព័ត៌មានលំអិតអំពីជនរងគ្រោះ និងគ្រួសារ ការព្យាបាល និង សុខភាព ព័ត៌មានលំអិតអំពីការកាត់ក្តី និង ស្ថានភាពនៃការតាមដានត្រួតពិនិត្យ។ បញ្ជីសំណួរសម្រាប់ការជួញដូរ មានសំណួរអំពីព័ត៌មានជាមូលដ្ឋាន វិធីសាស្ត្រនៃការផ្តួចផ្តើម គោលបំណងនៃការជួញដូរ លទ្ធផលនៃការជួញដូរ ព័ត៌មានអំពីអ្នកជួញដូរ ព័ត៌មានអំពីជនរងគ្រោះ និង គ្រួសារ ការព្យាបាល និង សុខភាព ការសង្គ្រោះ និង ធ្វើមាតុភូមិនិវត្តន៍ ព័ត៌មានលំអិតអំពីការកាត់ក្តី និង ស្ថានភាពនៃការតាមដានត្រួតពិនិត្យ។ ការបង្កើតឡើងនៃ បញ្ជីសំណួរទាំងនេះគឺផ្អែកលើការពិនិត្យឡើងវិញនូវឯកសារ ឬ ឧបករណ៍ផ្សេងៗ របស់អង្គការនានា។ ប៉ុន្តែដោយសារតែ ពេលវេលា និង ធនធានរបស់ពួកគេមានកំណត់មានតែ ១១អង្គការប៉ុណ្ណោះដែលប្រើបញ្ជី សំណួរដែលផ្តល់ជូននោះផ្ទាល់[2] ចំណែកឯអង្គការផ្សេងទៀតប្រើទម្រង់ឯកសាររបស់ពួកគេ[3]។ ទោះជាយ៉ាងណា ក៏ដោយគម្រោងប្រើប្រាស់តែព័ត៌មានដែលត្រូវការសម្រាប់ប្រព័ន្ធទិន្នន័យរបស់ខ្លួនប៉ុណ្ណោះ។

របាយការណ៍នេះមាន៣ផ្នែក ផ្នែកទី១ រៀបរាប់នូវស្ថានភាពទូទៅនៃបញ្ហាការរំលោភសេពសន្ថវៈ និង ជួញដូរកុមារនៅកម្ពុជា និងការដកស្រង់ពីឯកសារ និង របាយការណ៍គម្រោងរបស់អង្គការដែលពាក់ព័ន្ធមួយចំនួន។ ផ្នែកទី២ និយាយអំពីទិន្នន័យដែលបានរៀបរាប់ស្តីអំពីការរំលោភ និង ទី៣ អំពីទិន្នន័យដែលបានរៀបរាប់ស្តីអំពីការជួញដូរ។

ផ្នែកនៃការរំលោភតំណាងឱ្យករណីរំលោភសរុបចំនួន៥៥៨ ដែលបានរាយការណ៍ដោយអង្គការ[4] ចំនួន១៧ នៅក្នុង ២១ ខេត្ត-ក្រុង (មើលឧបសម្ព័ន្ធ)។ ផ្នែកនៃការជួញដូរតំណាងឱ្យករណីសរុប៧៦១ ដែលផ្តល់ដោយអង្គការ[5] ចំនួន ១៧ ក្នុង ១៩ ខេត្ត-ក្រុង (មើលឧបសម្ព័ន្ធសម្រាប់ព័ត៌មានលំអិត)។ ដោយបានទទួលនូវ ព័ត៌មានដែលអាចប៉ះពាល់ដល់ជនរងគ្រោះ អ៊ិកផាតបានធានាការសម្ងាត់របស់ទិន្នន័យទាំងឡាយជាមួយដៃគូ ទាំង ផ្លូវការ[6] និង មិនផ្លូវការ ដើម្បីការពារអត្តសញ្ញាណរបស់ជនរងគ្រោះ។

---

[2] AFESIP, CCASVA, CoC, Goutte D'Eau, Hagar, Homeland, KMR, KT, PJJ, WVC

[3] APLE, BAKC, CCHDO, CCPCR, CWCC, HCC, LAC, NGOCRC, OH

[4] AFESIP, APLE, BAKC, CCASVA, CCHDO, CCPCR, CDP, CWCC, Hagar, HCC, Homeland, LAC, NGOCRC, OH, PJJ, VCAO, WVC

[5] CCHDO, CCPCR, CDP, CoC, CWCC, CWDA, Goutte D'Eau, Hagar, HCC, Homeland, KMR, KT, LAC, NGOCRC, PJJ and WVC

[6] MoUs ត្រូវបានធ្វើឡើងជាមួយ AFESIP CWCCនិង WVC តាមសំណូមពររបស់ពួកគេ

## ដែនកំណត់នៃការសិក្សា

ក្របខណ្ឌជាទូទៅរបស់ការសិក្សាមានលក្ខណៈរួម និង ផ្តោតលើតម្រូវការដើម្បីសម្របសម្រួលការងាររបស់ក្រុម ផ្សេងៗ ដោយចែករំលែកព័ត៌មាន តែទោះជាយ៉ាងណាក៏ដោយ វាក៏កំណត់ឱ្យការសិក្សាតាមរយៈកម្មវិធី ដែលមានភាពលម្អៀង លើប្រភពនៃព័ត៌មានអំពីករណីផ្សេងៗ។ ដូចនេះវាសំខាន់ណាស់ ដែលចាំក្នុងចិត្តថាការរកឃើញរបស់ការ សិក្សានេះជាចម្បងត្រូវបានកំណត់ ដោយបរិបទជាក់ស្តែងរបស់អង្គការដែលចូលរួម ដែលត្រូវបាន បរិយាយដោយសង្ខេបនៅក្នុងឧបសម្ព័ន្ធ។ ជាបន្ថែមទៀត វាគួរត្រូវបានបញ្ជាក់ឡើងវិញថាទិន្នន័យ ដែលបានបង្ហាញនេះ មិនតំណាងឱ្យប្រទេសទាំងមូលនោះទេ តែវាមានសារសំខាន់មិនតិចជាងនេះនោះទេ។

## II. ស្ថានភាពទូទៅ

បន្ទាប់ពីសង្គ្រាម និង ជម្លោះស៊ីវិលច្រើនឆ្នាំ កម្ពុជាបានស្ថិតនៅតាមវិថីនៃការព្យាបាល និង កសាងឡើងវិញដោយរើសយកអ្វីៗដែលនៅសេសសល់ ជាលក្ខណៈរូបរាង សេដ្ឋកិច្ច នយោបាយ និង ហេដ្ឋារចនាសម្ព័ន្ធសង្គម។ ប្រទេសនេះក៏បានដោះស្រាយទិដ្ឋភាពជាអរូបិយជាច្រើន នៃការអភិវឌ្ឍដោយផ្តោតលើការអភិវឌ្ឍធនធានមានតម្លៃបំផុតរបស់ប្រជាជនខ្លួន តាមរយៈការអប់រំ និង បណ្តុះបណ្តាលដើម្បីជំនួសឱ្យអ្នកដែលត្រូវបានសម្លាប់ ដោយរបបខ្មែរក្រហម។ ទោះជាមានភោគផលដំបូង និង កិច្ចខិតខំប្រឹងប្រែងបន្តបន្ទាប់ក៏ដោយ កម្ពុជានៅតែជាប្រទេសមួយក្នុងចំណោម ប្រទេសក្រីក្រជាងគេក្នុងតំបន់ដោយមានប្រជាជនចំនួន៣៤.៧% ដែលត្រូវចាត់ទុកថាក្រីក្រ[៧]។

ប្រទេសកម្ពុជាមានប្រជាជនប្រមាណជា១៣.៤ លាននាក់ នៅឆ្នាំ២០០៤ ដែលមានស្ត្រីចំនួន ៥១%។ មួយផ្នែកដោយសារតែសង្គ្រាមប្រជាជនរបស់ប្រទេសនេះភាគ ច្រើនជាមនុស្សដែលមានវ័យក្មេង។ នៅឆ្នាំ១៩៩៤ ៤៧%នៃប្រជាជនគឺមានអាយុតិចជាង១៥ឆ្នាំ។ ចំនួននេះថយចុះបន្តិច នៅឆ្នាំ២០០៤ គឺមាន៣៨.១%។ លើសពីនេះទៅទៀត ក្រុម អាយុពី១៥ទៅ១៩ឆ្នាំ ស្មើនឹង១២.៧% ដែលមានន័យថាជិតពាក់កណ្តាលនៃប្រជាជនសរុបគឺជាកុមារ ឬ អ្នកដែលមានអាយុក្រោម១៨ឆ្នាំ[៨]។ *មើលតារាង១.០ និងតួលេខ ១.០* និងតួលេខដែលជិតនិងទ្រេត។ យោងលើរចនាសម្ព័ន្ធប្រជាជន បច្ចុប្បន្ន និងអត្រាមានកូន ការគ្រោងទុកជាផ្លូវការបានបង្ហាញថា៤៤ភាគរយ នៃប្រជាជនរបស់ប្រទេសទាំងមូលក្នុងឆ្នាំ ២០១១ នឹងធ្លាក់មកនៅ អាយុពី០-១៩ឆ្នាំ[៩]។

**តារាង ១. រចនាសម្ព័ន្ធរបស់ប្រជាជនកម្ពុជា ឆ្នាំ២០០៤**

| | ភាគរយ | | |
|---|---|---|---|
| **អាយុ** | **ស្រី** | **ប្រុស** | **សរុប** |
| *០ - ៤* | *១០.៩* | *១១.៩* | *១១.៤* |
| *៥ - ៩* | *១២.៧* | *១៣.៨* | *១៣.២* |

---

[7] រាជរដ្ឋាភិបាលកម្ពុជា ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ ច្បាប់ចុងក្រោយ ថ្ងៃ២៧ ខែមករា ឆ្នាំ២០០៦ (ការប៉ាន់ប្រមាណ២០០៤)

[8] CSES ប្រើអាយុ០-៤ ៥-៩ ១០-១៤ ១៥-១៩

[9] វិទ្យាស្ថានជាតិស្ថិតិ/ក្រសួងផែនការ ២០០៤ ការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា ភ្នំពេញ:NIS/MoP

| | | | |
|---|---|---|---|
| ***១០ - ១៤*** | ***១២.៩*** | ***១៤.២*** | ***១៣.៥*** |
| ***១៥ - ១៩*** | ***១២.០*** | ***១៣.៤*** | ***១២.៧*** |
| ២០ - ២៤ | ១០.៥ | ១១.០ | ១០.៧ |
| ២៥ - ២៩ | ៦.២ | ៥.៩ | ៦.១ |
| ៣០ - ៣៤ | ៦.៤ | ៦.២ | ៦.៣ |
| ៣៥ - ៣៩ | ៦.១ | ៥.៨ | ៦.០ |
| ៤០ - ៤៤ | ៥.៤ | ៥.១ | ៥.៣ |
| ៤៥ - ៤៩ | ៤.៤ | ៣.៣ | ៣.៩ |
| ៥០ - ៥៤ | ៣.៥ | ២.៦ | ៣.១ |
| ៥៥ - ៥៩ | ២.៦ | ២.០ | ២.៣ |
| ៦០ - ៦៤ | ២.០ | ១.៦ | ១.៨ |
| ៦៥ - ៦៩ | ១.៦ | ១.២ | ១.៤ |
| ៧០ - ៧៤ | ១.២ | ០.៩ | ១.០ |
| ៧៥+ | ១.៤ | ១.០ | ១.២ |
| | | | |
| សរុប | ១០០.០ | ១០០.០ | ១០០.០ |

ប្រភព : CSES ២០០៤

**តួលេខ ១. រចនាសម្ព័ន្ធរបស់ប្រជាជនកម្ពុជា ឆ្នាំ២០០៤**




ប្រភព : CSES ២០០៤

មិនចាំបាច់ពិពណ៌នានោះទេ ថាតម្រូវការចម្បងបំផុតសម្រាប់ក្រុមអាយុនេះគឺការអប់រំ តែវាមានការខ្វះខាតសាលា ជាពិសេសសម្រាប់អនុវិទ្យាល័យនៅតាមជនបទ បើទោះជា កម្មវិធីការអប់រំសម្រាប់ទាំងអស់គ្នារបស់កម្ពុជា (EFA)

ដែលមានបំណងសម្រេចបាននូវការអប់រំជាសកលសម្រាប់បឋម និងមធ្យមសិក្សានៅត្រឹមឆ្នាំ២០១០[10] ។ មានតែសាលាបឋមសិក្សាចំនួន ៦១៨០ និងអនុវិទ្យាល័យចំនួនតែ ៨០០ប៉ុណ្ណោះនៅទូទាំងប្រទេស ហើយទោះជាអត្រាចុះឈ្មោះចូលរៀនសរុបមានកម្រិត ខ្ពស់រហូតដល់ ៩១.៩ភាគរយ (៩៣ភាគរយសម្រាប់កុមារា និង៩០.៧ភាគរយសម្រាប់កុមារី) ចំនួននេះមានការថយចុះ ជាខ្លាំងសម្រាប់កម្រិតអនុវិទ្យាល័យដែលមានតែ ២៦.១ភាគរយ (២៧.១ភាគរយសម្រាប់សិស្សប្រុស និង ២៤.៨ ភាគរយសម្រាប់សិស្សស្រី)[11] ។ ជំនួសមកវិញកុមារភាគច្រើនបាន នឹង កំពុងធ្វើការរួចជាស្រេច ដើម្បីជួយផ្គត់ ផ្គង់ដល់គ្រួសាររបស់គេ។ កុមារា និង កុមារីភាគច្រើនដែលមានអាយុចន្លោះពី១៥-១៩ឆ្នាំបានចូលទៅក្នុងកម្លាំងពលកម្ម រួចជាស្រេច ដោយមានចំនួនក្មេងស្រីច្រើនជាងក្មេងប្រុសបន្តិច។ សូម្បីតែក្រុមអាយុពី១០-១៤ឆ្នាំក៏ត្រូវបង្ខំឱ្យធ្វើការដែរ តែមានចំនួនក្មេងប្រុសច្រើនជាងក្មេងស្រីវិញ ។ *មើលតារាង ២.០* ។

**តារាង ២. កុមារី និងកុមារាដែលស្ថិតនៅក្នុងកម្លាំងពលកម្ម**

| | កុមារី | កុមារា |
|---|---|---|
| អត្រាកំលាំងពលកម្មដែលចូលរួមដោយក្រុមក្មេងអាយុ១៥-១៩ ឆ្នាំ | ៧៣.១% | ៧២.៥% |
| អត្រាកំលាំងពលកម្មដែលចូលរួមដោយក្រុមក្មេងអាយុ១០-១៤ ឆ្នាំ | ៤៧.១% | ៤៩.១% |

ប្រភព : CSES ២០០៤

## ការរំលោភ

កុមារី និង កុមារាកម្ពុជាប្រឈមនឹងបញ្ហាយ៉ាងធ្ងន់ធ្ងរនៃការរំលោភសេពសន្ថវៈ និងការកេងប្រវ័ញ្ចផ្លូវភេទ។ ប្រភពអង្គការបានបង្ហាញថា ការរាយការណ៍ពីករណីរំលោភបានកើនឡើងយ៉ាងគួរកត់សម្គាល់ពីឆ្នាំ១៩៩៧ ដល់ ២០០៥[12] ។ របាយការណ៍របស់លីកាដូស្តីពីអំពើហិង្សាប្រឆាំងស្ត្រីឆ្នាំ២០០៦ បានកត់សម្គាល់នូវការកើនឡើង នៃការរាយការណ៍ពីបទឧក្រិដ្ឋរំលោភ ដោយយោងលើស្ថិតិផ្ទាល់របស់ពួកគេពីឆ្នាំ២០០០-២០០៥ ស្ថិតិរបស់អង្គការអាដហុក ឆ្នាំ២០០០-២០០៥ និងស្ថិតិរបស់អង្គការ CWCC ឆ្នាំ១៩៩៧-២០០៥។ ចំនួនករណីរំលោភរបស់ CWCC បានកើនឡើងទ្វេរ រវាងខែមករា ឆ្នាំ២០០១ និងខែមេសាឆ្នាំ២០០២ (២២៧ករណី)។ ហើយនៅក្នុងកំឡុងពេល (ខែកក្កដា ឆ្នាំ២០០៣-ខែធ្នូ២០០៥) មណ្ឌលរបស់គេតែមួយគត់នៅខេត្តបន្ទាយមានជ័យ បានទទួលករណីរំលោភចំនួន៨១។ ជនរងគ្រោះទាំងនោះភាគច្រើនគឺជាកុមារ។ ក្រុមអាយុ១០ឆ្នាំ និងក្រោម១០ឆ្នាំ និងរវាង១១ឆ្នាំនិង២០ឆ្នាំ មានចំនួន១៨ភាគរយនិង៦៤ភាគរយ នៃចំនួន

[10] កម្មវិធីអប់រំមានរយៈពេលសរុប៩ឆ្នាំ ថ្នាក់ទី១-៦ សម្រាប់បឋមសិក្សារ និងថ្នាក់ទី៧-៩ សម្រាប់អនុវិទ្យាល័យ

[11] វិទ្យាស្ថានជាតិស្ថិតិ/ក្រសួងផែនការ ២០០៤ ការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា ភ្នំពេញ: NIS/MoP

[12] ស្ថិតិលីកាដូ ពីឆ្នាំ២០០០-២០០៥, ស្ថិតិអាដហុក ២០០០-២០០៥ និងស្ថិតិ CWCC ១៩៩៧-២០០៥(លីកាដូ ២០០៦) ដូចដែលដកស្រង់នៅក្នុងរបាយការណ៍លីកាដូអំពីអំពើហិង្សាប្រឆាំងនឹងស្ត្រី ២០០៦

ជនរងគ្រោះ[១៣] ។ អង្គការអាដហុកក៏បានរាយការណ៍ផងដែរថាឆ្នាំ២០០៤ ករណី រំលោភភាគច្រើនដែលគេបានចងក្រងឯកសារ មានពាក់ព័ន្ធនឹងជនរងគ្រោះដែលមានអាយុតិចជាង១៨ឆ្នាំ ហើយ៤ ភាគរយក្មេងជាងអាយុ៥ឆ្នាំ ។

សារព័ត៌មាន បានរាយការណ៍ពីករណីរំលោភជាក្រុមដែលកើតឡើងនៅក្នុងឆ្នាំថ្មីៗនេះ ក៏បានធ្វើឱ្យមានការចាប់អារម្មណ៍ដែរ ។ ការរំលោភជាក្រុមទៅលើអ្នករកស៊ីផ្លូវភេទ នៅតំបន់ជាយក្រុងត្រូវបានរាយការណ៍ ក្នុងឆ្នាំ២០០៣ ប៉ុន្តែឆ្នាំ២០០៤ បទពិសោធន៍ស្រដៀងគ្នាគឺត្រូវបានចងក្រងនោះគឺក្នុងចំណោមសិស្សសាលានៅតាមជនបទ ដោយអ្នកនៅលីវ និង អ្នកដែលរៀបការហើយក៏ត្រូវបានគេយកជាគោលដៅ ហើយពេលខ្លះពាក់ព័ន្ធ ជាមួយបុរស ពី២ទៅ ៥នាក់[១៤] ។

ថ្វីបើមានរបាយការណ៍របស់អង្គការនិមួយៗ ក៏ដោយក៏គ្មានស្ថិតិទូលំទូលាយស្តីពីបញ្ហាដែលកំណត់វិសាលភាពរបស់ វានោះទេ ដោយសារតែកត្តាមួយចំនួន ។ ករណីរំលោភជានិច្ចកាលមិនត្រូវបានគេរាយការណ៍ទេព្រោះតែបរិបទនៃ វប្បធម៌ដែលករណីនោះកើតឡើងដែលជាញឹកញាប់ក្លាយជាការទទួលខុសត្រូវ និង ជាបន្ទុករបស់ជនរងគ្រោះជាជាងរបស់ជនល្មើស ។ ប្រពៃណីដែលគេរំពឹងទុកថាស្ត្រីនៅមានបរិសុទ្ធរហូតដល់ពេលរៀបការ ក៏ធ្វើឱ្យជនរងគ្រោះដែលភាគច្រើនជាក្មេងស្រីដែលមិនទាន់រៀបការនៅស្ងៀមស្ងាត់ដោយខ្លាចគេថាខូច និង មិនសមរៀបការ ។ ការរំលោភក៏ត្រូវបានគេគិតថាជារឿងអាម៉ាស់ និងជាមូលហេតុមួយនៃការបាក់មុខរបស់ជនរងគ្រោះ និងក្រុមគ្រួសារអញ្ចឹងហើយ ត្រូវបានគេទុកជាការសម្ងាត់ហើយមិនរាយការណ៍ ។ វាត្រូវបានគូសបញ្ជាក់យ៉ាងច្បាស់ ដោយករណីថ្មីៗនេះដែល កុមារីអាយុ១២ឆ្នាំម្នាក់មកពីខេត្តសៀមរាប ដែលម្តាយរបស់នាងមានប្រតិកម្ម ដោយគ្មានការអាណិតអាសូរចំពោះការឈឺ ចាប់របស់កូនស្រីនៅពេលគាត់និយាយថា "ខ្ញុំមានអារម្មណ៍ខ្មាស់គេណាស់នៅពេលដែលខ្ញុំនិយាយប្រាប់អ្នកភូមិថា កូនស្រីរបស់ខ្ញុំត្រូវគេចាប់រំលោភ" ហើយថែមទាំងទាំងជេរ និង វាយនាងនៅពេលដែលនាងប្រាប់ម្តាយរបស់នាង អំពីការរំលោភទៀតផង[១៥] ។

ជនរងគ្រោះអាចស្ទាក់ស្ទើរជាងនេះក្នុងការរាយការណ៍ដោយសារតែ : មិនជឿជាក់លើប្រព័ន្ធយុត្តិធម៌ (ជនរងគ្រោះអាចព្រួយបារម្ភអំពីអំពើពុករលួយនៅក្នុងប្រព័ន្ធយុត្តិធម៌) ថ្លៃកាត់ទោស (មិនមានការយកថ្លៃស្របច្បាប់របស់តុលាការទេសម្រាប់ដំណើការរឿងក្តីឧក្រិដ្ឋ តែទោះជាយ៉ាងណាក៏ដោយក្នុងការអនុវត្តជាក់ស្តែងថ្លៃលាក់កំបាំងផ្សេងៗត្រូវបានគេទាមទារនៅតាមកម្រិតផ្សេងៗដោយសារតែមន្ត្រីពុករលួយ ភ័យខ្លាចការសងសឹកពីអ្នកប្រព្រឹត្ត (ជាពិសេសនៅពេលដែលអ្នកប្រព្រឹត្តស្ថិតក្នុងតំណែងដែលមានអំណាចលើជនរងគ្រោះ) និងការសងជំងឺចិត្តក្រៅផ្លូវការការដោះស្រាយ រវាងអ្នកប្រព្រឹត្ត និង ជនរងគ្រោះ (មានករណីជាច្រើនត្រូវបានដោះស្រាយក្រៅប្រព័ន្ធតុលាការ)[១៦] ។

---

13 របាយការណ៍លទ្ធផលគម្រោងជួយស្រីមានវិបត្តិនៅខេត្តបន្ទាយមានជ័យពីខែកក្កដា២០០៣-ខែធ្នូ២០០៥

14 របាយការណ៍សិទ្ធមនុស្ស អាដហុកឆ្នាំ២០០៤

15 ការសែតរស្មីខេមបូឌាដេលី, ថ្ងៃទី ៨ ខែមករា ឆាំ២០០៧ "កុមាររងគ្រោះដោយការជួញដូរអាយុ១២ ខ្លាចការនិយាយជាមួយ នគរបាល អង្គការ" ដោយ ឆាយ ចន្ទីដា

16 របាយការណ៍ ឆ្នាំ២០០៥ របស់ លីកាដូ ស្តីពីអំពើហិង្សាប្រឆាំងស្ត្រី ឆ្នាំ២០០៦

ច្បាប់របស់កម្ពុជាទទួលស្គាល់ថា ការចាប់រំលោភជាបទឧក្រិដ្ឋ ហើយត្រូវបានដោះស្រាយភាគច្រើនដោយច្បាប់ព្រហ្មទណ្ឌអន្តរកាលរបស់អ៊ុកតាក់ និង ច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ឆ្នាំ២០០១។ មាត្រា៣៣របស់ច្បាប់ អ៊ុនតាក់សរសេរថា :

១. ជនណាក៏ដោយដែលរំលោភសេពសន្ថវៈ ឬ ប៉ុនប៉ងរំលោភសេពសន្ថវៈលើជនម្នាក់ទៀត ទោះភេទដូចគ្នា ឬ មិនដូចគ្នាក៏ដោយត្រូវមានទោសពីបទរំលោភសេពសន្ថវៈហើយត្រូវផ្តន្ទាទោសដាក់គុកជាបទឧក្រិដ្ឋពី៥ឆ្នាំទៅ១០ ឆ្នាំ[១៧] ។
២. បទរំលោភសេពសន្ថវៈគឺគ្រប់អំពើបញ្ចូលអង្គជាតិដោយឃោរឃៅ ដោយបង្ខំ ឬដោយមិនដឹងខ្លួនជាមុន។ ប្រសិនបើការរំលោភសេពសន្ថវៈបានត្រូវប្រព្រឹត្តឡើងដោយការគំរាមកំហែង និងអាវុធទៅលើស្ត្រីមានផ្ទៃពោះ លើជនមានជំងឺ ឬជនមានសតិវិបល្លាស ឬពិការរាងកាយ ឬធ្វើឡើងដោយមានអ្នកប្រព្រឹត្តពីរនាក់ ឬច្រើននាក់ ឬដោយមានអ្នកសមគំនិត ឬបើការសេពសន្ថវៈនោះត្រូវប្រព្រឹត្តឡើងដោយជនដែលមានអំណាច លើអ្នករងគ្រោះ ទណ្ឌកម្មដែលត្រូវអនុវត្តគឺដាក់គុកជាបទឧក្រិដ្ឋពី១០ឆ្នាំ ទៅ១៥ឆ្នាំ[១៨] ។

ច្បាប់នេះជួយការពារកុមារបន្ថែមទៀតដោយក្រោយមកសរសេរថា :
ប្រសិនបើការរំលោភសេពសន្ថវៈបានត្រូវប្រព្រឹតឡើង ដោយការគំរាមកំហែងនឹងអាវុធទៅលើស្ត្រីមានផ្ទៃពោះ លើជនមានជំងឺ ឬជនមានសតិវិបល្លាស ឬពិការរាងកាយ ឬធ្វើឡើងដោយមានអ្នកប្រព្រឹត្តពីរនាក់ ឬ ច្រើននាក់ ឬដោយមានអ្នកសមគំនិត ឬបើការសេពសន្ថវៈនោះត្រូវប្រព្រឹត្តឡើងដោយជនដែលមានអំណាចលើអ្នករងគ្រោះ ទណ្ឌកម្មដែលត្រូវអនុវត្តគឺដាក់គុកដោយតម្រូវឱ្យធ្វើការពី១៥ឆ្នាំ ទៅ២០ឆ្នាំ។

ទោះជាមានបញ្ញតិច្បាប់ទាំងនេះ អ្នករំលោភជាច្រើនមិនត្រូវបានគេដាក់ទោសដោយសារតែកត្តាមួយចំនួន ដែលបានរៀបរាប់ខាងលើ។ បន្ថែមពីលើតម្រូវការអនុវត្តច្បាប់ឱ្យមានភាពប្រសើរ នៅមានតម្រូវការជាច្រើនទៀត ដែលត្រូវការដោះស្រាយ។ ជនរងគ្រោះ និង គ្រួសាររបស់គេប្រឈមនឹងការជះឥទ្ធិពលនៃការរំលោភលើជីវិត របស់ពួកគេជុំវិញទិដ្ឋភាពផ្លូវកាយ អារម្មណ៍ ផ្លូវចិត្ត និងសូម្បីតែបញ្ហាសេដ្ឋកិច្ចដែលអាចនឹង កាន់តែរីករាលដាលដោយសារតែវប្បធម៌ និងអាកប្បកិរិយារបស់សង្គមដែលធ្វើឱ្យមានស្លាកស្នាមលើជនរងគ្រោះ។ សេវាភាគច្រើនគឺផ្តល់ដោយ អង្គការមិនមែនរដ្ឋាភិបាល ប៉ុន្តែដាច់ៗដោយឡែកពីគ្នាហើយក៏មិនត្រូវបានសម្របសម្រួលដោយសារតែធនធានមានកំណត់។ នាយកដ្ឋានរបស់ រដ្ឋាភិបាលជាមួយនឹងអាណត្តិការងារពាក់ព័ន្ធគ្នាជាទូទៅពុំមានធនធាន និងជំនាញគ្រប់គ្រាន់ក្នុងការដោះស្រាយបញ្ហា។

[17] រាជរដ្ឋាភិបាលកម្ពុជា បញ្ញតិទាក់ទងនឹងប្រពន្ធ័តុលាការ និងច្បាប់ព្រហ្មទណ្ឌ និង និតិវិធីដែលអាចប្រើបាននៅកម្ពុជាក្នុងសម័យអន្តរកាល, សេចក្តីសម្រេចថ្ងៃ១០ ខែកញ្ញា ឆ្នាំ១៩៩២

[18] ព្រះរាជាណាចក្រកម្ពុជា ក្រសួងកិច្ចការនារី កិច្ចការនារីក្នុងឯកសារច្បាប់ ឧបត្ថម្ភដោយគម្រោងរបស់ GTZ ស្តីពីការផ្សព្វផ្សាយសិទ្ធិស្ត្រី

## ការជួញដូរ

ការជួញដូរមនុស្សបានស្ថិតនៅក្នុងរបៀបវារៈរបស់រាជរដ្ឋាភិបាល ម្ចាស់ជំនួយ និងអង្គការជាច្រើនអស់រយៈពេលជាច្រើនឆ្នាំមកហើយ ។ ប្រទេសកម្ពុជាត្រូវបានគេស្គាល់ជាប្រទេសបញ្ជូន ឆ្លងកាត់ និងគោលដៅសម្រាប់ការជួញដូរ ។ ទោះជាការជួញដូរជាញឹកញាប់មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយពេស្យាចារ តែវាក៏ត្រូវបានគេធ្វើក្នុងគោល បំណងសុំទាន និងលក់ដូរ កេងប្រវ័ញ្ចពលកម្ម ស្មុំកូន និងរៀបការផងដែរ ។ កុមារត្រូវបានជួញដូរក្នុងគោលបំណងទាំងអស់នេះ បើទោះជាគ្មានស្ថិតិតំណាងដើម្បីអធិប្បាយនូវហេតុការណ៍នេះនៅកម្រិតថ្នាក់ជាតិក៏ដោយ ។ ព័ត៌មាន ស្តីពីការជួញដូរភាគច្រើនប្រមូលផ្តុំលើការជួញដូរផ្លូវភេទ និងភាគច្រើន ផ្អែកលើការសិក្សាក្នុងស្រុក ឬក៏ជាការប៉ាន់ ប្រមាណទូលំទូលាយ ដូច្នេះវាមានវិសាលភាពកំណត់ ។ ទោះជាយ៉ាងណាក៏ដោយការជួញដូរស្ត្រី និង កុមារត្រូវ ឃើញថាជាអាជីវកម្មជោគជ័យមួយជាពិសេសនៅតាមជាយក្រុងដូចជាភ្នំពេញ សៀមរាប និងបាត់ដំបង ហើយនិង តំបន់តាមព្រំដែនដូចជាខេត្តបន្ទាយមានជ័យ ក្រុងព្រះសីហនុ កោះកុង[១៩] អង្គការ CWCC ប៉ាន់ប្រមាណថាស្ត្រី និងកុមារ៨០០នាក់ ត្រូវបានគេជួញដូរឬរត់ពន្ធ ទៅក្នុងប្រទេសថៃ និង ប្រមាណជា៤០០នាក់ ត្រូវបានគេនិរទេសមកកាន់ប្រទេសកម្ពុជា វិញជារៀងរាល់ខែដោយអាជ្ញាធរថៃ ។ ស្ត្រី និងកុមារកម្ពុជាត្រូវបានគេជួញដូរទៅប្រទេសម៉ាឡេស៊ី ដើម្បីបង្ខំធ្វើពេស្យាចារ ធ្វើការរោងចក្រ និង បំរើតាមផ្ទះ ។ ការប៉ាន់ប្រមាណមួយបាននិយាយថាស្ត្រីវៀតណាមពី២០,០០០ ទៅ៣០,០០០នាក់នៅកម្ពុជា ជាអ្នករកស៊ីផ្លូវភេទ[២០] ។

វាត្រូវបានប៉ាន់ប្រមាណថា២០.២ភាគរយនៃអ្នករកស៊ីផ្លូវភេទ នៅក្នុងប្រទេសត្រូវបានគេជួញដូរ ហើយក្នុងចំណោម អ្នករកស៊ីផ្លូវភេទចំនួន២០,៨២៩នាក់ នៅតាមផ្ទះបន ហាងម៉ាស្សា តាមផ្លូវ និងរង្គសាលក្នុងឆ្នាំ២០០៣ ចំនួន៣.៧ភាគរយជាកុមារ[២១] ។

ទោះជាគ្មានភស្តុតាងក្នុងទម្រង់ជាប្រព័ន្ធ និង ទិន្នន័យតំណាង ដែលថាការជួញដូរមានការកើនឡើង តែខាងក្រោមនេះត្រូវបានគេរកឃើញថាជាការពិតនៅក្នុងឧស្សាហកម្មផ្លូវភេទនៅប្រទេសកម្ពុជាដោយផ្អែកលើការពិនិត្យមើលជាលក្ខណៈបរិមាណ និង ការសិក្សាដែលមានលក្ខណៈពិពណ៌នាផ្សេងៗកាលពី១០ឆ្នាំមុន[២២] ។

- ទោះជាបុរស និង កុមារាពាក់ព័ន្ធនឹងការងារផ្លូវភេទក៏ដោយ តែស្ត្រីមានលក្ខណៈច្រើនលើសលុប ។
- អាយុរបស់អ្នករកស៊ីផ្លូវភេទដែលបានរាយការណ៍មានពី១៣ និង៤៤ឆ្នាំ ។ អ្នករកស៊ីផ្លូវភេទភាគច្រើនមាន អាយុលើស១៨ឆ្នាំ មានចំនួនតិចតួចមានអាយុលើស២៧ឆ្នាំ ។ ភាគរយនៃពេស្យាចារកុមារអាយុក្រោម១៦ មានពី១

---

[19] MOWA ២០០២

[20] UNIFEM, WB, ADB, UNDP & DFID/UK. 2004. ចំណែកដ៏ត្រឹមត្រូវសម្រាប់ស្ត្រី : ការប៉ាន់ប្រមាណយេនឌ័រកម្ពុជា ។ UNIFEM, WB, ADB, UNDP & DFID/UK ភ្នំពេញ

[21] Steinfatt ដូចដែលបានដកស្រង់ នៅក្នុងការពិនិត្យឡើងវិញនៃការស្រាវជ្រាវមួយទសវត្សស្តីពីការជួញដូរមនុស្ស របស់ មូលនិធិអាស៊ី និងមជ្ឈមណ្ឌលដើម្បីការសិក្សាជាន់ខ្ពស់ កម្ពុជា ខែឧសភា ឆ្នាំ២០០៦ ដោយ Derks, Annuska, Roger Henke and Ly Vanna

[22] ការពិនិត្យឡើងវិញនៃការស្រាវជ្រាវមួយទសវត្សស្តីពីការជួញដូរមនុស្ស របស់ មូលនិធិអាស៊ី និងមជ្ឈមណ្ឌលដើម្បីការសិក្សាជាន់ខ្ពស់ កម្ពុជា ខែឧសភា ឆ្នាំ២០០៦ ដោយ Derks, Annuska, Roger Henke

ភាគរយ (អាដហុក ១៩៩៩) ៣ភាគរយ (អារ៉ិនសិន ២០០៤) និង ៨ភាគរយ (CHRRC ១៩៩៧) រហូតដល់ ២៦ភាគរយ (Thomas/Pasnik S2)

- អ្នករកស៊ីផ្លូវភេទភាគច្រើនជាជនជាតិខ្មែរ ក្រុមបន្ទាប់គឺជនជាតិវៀតណាម ដែលមានទំនោរក្នុងការប្រមូលផ្តុំនៅតំបន់ជាក់លាក់។ រហូតមកទល់ពេលនេះ ព័តិមានមិនច្បាស់ការក៏មានដែរស្តីពីស្ត្រីជនជាតិភាគតិច និង ជនជាតិផ្សេងៗ(អឺរ៉ុបខាងកើត ចិន ថៃ)ធ្វើការនៅក្នុងអាជីវកម្មផ្លូវភេទនៅកម្ពុជា
- អ្នករកស៊ីផ្លូវភេទកម្ពុជាមកពីគ្រប់កន្លែងនៃប្រទេស ខេត្តនានាដែលមានប្រជាជនច្រើន និងនៅជិតក្រុង/តំបន់ទេសចរណ៍ (ខេត្តកំពង់ចាម បាត់ដំបង កណ្តាល ភ្នំពេញ និងព្រៃវែង)មានទំនោរធ្វើឱ្យមានការកើនឡើងខ្ពស់ជាងខេត្តដើមដែលបានរាយការណ៍។
- អ្នករកស៊ីផ្លូវភេទផ្លាស់ទីជានិច្ច និងផ្លាស់ប្តូរញឹកញាប់ទៅតាមផ្ទះបន អត្រាដែលកើនឡើងខ្ពស់នេះ ទាក់ទងនឹងប្រភេទការងារបណ្តោះអាសន្នដូចដែលបានបញ្ជាក់ដោយរយៈពេលមធ្យមរបស់ស្ត្រីដែល ស្ថិតនៅក្នុងការរកស៊ីផ្លូវភេទ (White et al 2004, Catalla 2004b, Arensen 2004, ADHOC 1999, de Ling van Wijngaarden d.d.) Yet Arensen (2004:28) បានរកឃើញថា និយាយដោយប្រៀបធៀបអ្នកផ្តល់ចម្លើយ ដែលត្រូវបានគេជួញដូរបានធ្វើការរកស៊ីផ្លូវភេទនៅតាមខេត្តច្រើនជាង និង នៅតាមផ្ទះបនច្រើនជាងហើយបានរស់នៅក្នុងការរកស៊ីផ្លូវភេទយូរជាងអ្នកដែលមិនត្រូវបានគេជួញដូរ។

នៅក្រោមច្បាប់កម្ពុជាការជួញដូរគឺខុសច្បាប់យោងតាមច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្ស និង អំពើធ្វើអាជីវកម្មលើមនុស្ស និងដូចដែលបានចែងនៅក្នុងរដ្ឋធម្មនុញ្ញ (មាត្រា៤៦ "អំពើលក់ដូរមនុស្ស អំពើធ្វើអាជីវកម្មផ្នែកពេស្យាកម្ម និងអំពើអាសអាភាសដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ របស់នារីត្រូវហាមឃាត់") ដោយមានទោសដូចដែលមានចែងនៅ : (មាត្រា៣) ជនណាអូសទាញមនុស្ស ទោះបីស្រីឬប្រុស អនីតិជន ឬ នីតិជនមានសញ្ជាតិអ្វីក៏ដោយ ទោះបីសាម៉ីខ្លួនសុខចិត្ត ឬ មិនសុខចិត្ត ដោយវិធីបង្ខិតបង្ខំ គំរាមកំហែង ឬប្រើថ្នាំ សណ្តំស្មារតី និង សតិអារម្មណ៍ ដើម្បីពង្រត់យកទៅលក់ឬយកទៅធ្វើពេស្យាចារ ជននោះត្រូវផ្តន្ទាទោសដាក់ ពន្ធនាគារពី១០ឆ្នាំដល់១៥ឆ្នាំ។ បើជនរងគ្រោះជាអនីតិជនអាយុតិចជាង១៥ឆ្នាំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី១៥ឆ្នាំ ដល់២០ឆ្នាំ។

ទោះជាយ៉ាងណាក៏ដោយច្បាប់មិនបានក្តោបយកអ្វីដែលបង្កឱ្យមានដំណើរការជួញដូរ ដូច្នេះហើយវាមិនគ្រប់គ្រាន់នៅក្នុងបទបញ្ញតិរបស់វាដើម្បីផ្តន្ទាទោសអំពើជាក់លាក់ដូចដែលបានបញ្ជាក់នៅក្នុងពិធីសាររបស់អង្គការសហប្រជាជាតិ ដើម្បីទប់ស្កាត់ ហាមឃាត់ និងដាក់ទណ្ឌកម្មការជួញដូរមនុស្សជាពិសេសស្ត្រី និងកុមារដែលឱ្យនិយមន័យការជួញដូរថាជា :

"ការជ្រើសរើស ដឹកជញ្ជូន ផ្ទេរ ផ្តល់ទីកន្លែង ឬទទួលមនុស្ស ដោយមធ្យោបាយគំរាមកំហែង ឬប្រើកំលាំង ឬទម្រង់ផ្សេងទៀតនៃការបង្ខំ ពង្រត់ បោកបញ្ឆោត រំលោភអំណាច ឬតំណែងដែលមានភាពងាយរងគ្រោះ ឬផ្តល់ ឬទទួលសំណងឬផលប្រយោជន៍ដើម្បីទទួលបានការយល់ព្រមរបស់មនុស្សម្នាក់ដែលមានការត្រួតត្រាលើ មនុស្សម្នាក់ទៀតដើម្បីគោលបំណងកេងប្រវ័ញ្ច។ ការកេងប្រវ័ញ្ចត្រូវគិតទាំងកម្រិតអប្បរមា ការកេងប្រវ័ញ្ច ដោយធ្វើសញ្ចារកម្មអ្នកដទៃឬទម្រង់

ផ្សេងទៀតនៃការកេងប្រវ័ញ្ចផ្លូវភេទ ពលកម្ម ឬ សេវាដោយបង្ខំ ទាសករ ឬ ការ អនុវត្តស្រដៀងទាសករ សេវភាព ឬ ការដកយកសរីរាង្គ" ។

ដោយសារតែមានភាពខ្វះខាតនៅក្នុងច្បាប់ និង កត្តាផ្សេងៗទៀត រដ្ឋាភិបាលកម្ពុជាមិនទាន់បានទទួលជោគជ័យក្នុងការដាក់ទោសលើការជួញដូរនៅឡើយ ។ នៅខែ មិថុនា ឆ្នាំ២០០៥ នាយកដ្ឋានសហរដ្ឋអាមេរិក[២៣] បានចេញរបាយការណ៍មួយដែលបានដាក់ប្រទេសកម្ពុជាចូលទៅក្នុងប្រភេទប្រទេសអន់ជាងគេលើពិភពលោក ក្នុងការដោះស្រាយការជួញដូរ ៖

**របាយការណ៍ជួញដូរមនុស្ស សម្រាប់ប្រទេសកម្ពុជា ( កម្រិត៣)**

ចេញដោយការិយាល័យតាមដាន និងបំបាត់ការជួញដូរមនុស្ស

ថ្ងៃទី ៣ ខែមិថុនា ឆ្នាំ២០០៥

រដ្ឋាភិបាលកម្ពុជាមិនបានគោរពតាមស្តង់ដារអប្បបរមា ដើម្បីលប់បំបាត់ការជួញដូរ និងមិនបាន ខិតខំក្នុងការលុបបំបាត់ការជួញដូរ ។ ប្រទេសកម្ពុជាត្រូវដាក់ក្នុងកម្រិតទី៣សម្រាប់ការខ្វះខាត នូវការរីកចម្រើនក្នុងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃការជួញដូរ ជាពិសេសការខកខានមិនបានកាត់ ទោសអ្នកជួញដូរ និងមន្ត្រីសាធារណៈដែលពាក់ព័ន្ធក្នុងការជួញដូរ ។ ក្នុងកំឡុងពេលឆ្នាំមុន រដ្ឋាភិបាលកម្ពុជាមិនបានចាត់វិធានការ ដែលមានប្រសិទ្ធិភាព ដើម្បីធានាថាអ្នកដែលទទួលខុសត្រូវ ចំពោះការវាយលុកមណ្ឌលរបស់អង្គការមួយ ដើម្បីរំដោះជនរងគ្រោះដោយការជួញដូរត្រូវបាន ទទួលខុសត្រូវ និងឈានដល់ការរកយុត្តិធម៌ ។ ការបរាជ័យរបស់រដ្ឋាភិបាលកម្ពុជា ក្នុងការដោះស្រាយបញ្ហាជួញដូរ ចោទជាបញ្ហាដែលប្រទេសនេះប្តេជ្ញាដើម្បីលប់បំបាត់ការជួញដូរ មនុស្ស ។ កិច្ចខិតខំប្រឹងប្រែងរបស់ កម្ពុជាប្រឆាំងការជួញដូរនៅតែខ្សោយដោយសារតែអំពើពុករលួយជាប្រព័ន្ធ និង ប្រព័ន្ធយុត្តិធម៌ គ្មានប្រសិទ្ធិភាព ។ រដ្ឋាភិបាលត្រូវតែចាត់វិធានការណ៍តឹងតែង ដើម្បីកាត់ទោសនិង ដាក់ទោស អ្នកជួញដូរ និង មន្ត្រីសាធារណៈដែលត្រូវបានរកឃើញថាពាក់ព័ន្ធក្នុងការជួញដូរ និង ប្រឈមនឹង អំពើពុករលួយនៅក្នុងប្រព័ន្ធយុត្តិធម៌ដែលរារាំងការកាត់ទោសអ្នកជួញដូរ ។

ការជួញដូរគឺជាដំណើរការវែងមួយដែលពាក់ព័ន្ធ និង ដំណាក់កាលជាច្រើន ហើយដែលជារឿយៗចាប់ផ្តើមពីការ ធ្វើទេសន្តរប្រវេសន៍ដូច្នេះហើយវាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធនៅពេលក្រោយមក ។ ការធ្វើទេសន្តរប្រវេសន៍ កំពុងតែក្លាយជាយន្តការមួយដើម្បីរស់រានមានជីវិតសម្រាប់ប្រជាជនក្រីក្រនៅតាមបណ្តាលខេត្តនានាដើម្បីស្វែងរកឱកាសការងារ និង សេវាកម្មផ្សេងៗនៅតាមតំបន់ដែលមានអភិវឌ្ឍន៍ច្រើនជាង ប៉ុន្តែជាទូទៅពួកគេមិនមាន ការអប់រំ និង មិនបានទទួលដំណឹង ។ ទេសន្តរប្រវេសមកពីជនបទដាច់ស្រយាលមិនអាចតទល់ និងការសន្យាក្លែងក្លាយអ្នកដែលថាជីវិត នឹងបានប្រសើរ និងទម្រង់ផ្សេងៗនៃការបោកបញ្ឆោតដោយអ្នកជួញដូរ ។ កុមារនិងយុវវ័យដែលស្ថិតនៅក្នុងកម្លាំង ពលកម្មក្លាយជាគោលដៅងាយស្រួលរបស់អ្នកជួញដូរជាពិសេសក្មេងស្រី និង ស្ត្រីវ័យក្មេងដោយសារតែវាពាក់ពន្ធ័ ទៅនឹងករិតវប្បធម៌ទាប

23

របស់ពួកគេ ជំនាញដែលមានកម្រិត និង ជម្រើសតិចតួចនៅក្នុងជីវភាពប្រចាំថ្ងៃ។ ឧទាហរណ៍ ជនរងគ្រោះដោយការជួញដូរ ៦០ភាគរយដែលបានជួយសង្គ្រោះដោយអង្គការ CWCC រវាងឆ្នាំ២០០៣ និង ២០០៥ គឺជាក្មេងស្រី និង ស្ត្រីវ័យក្មេង ហើយ៥៤ភាគរយត្រូវបានគេជួញដូរផ្លូវភេទ[២៤]។

ជនរងគ្រោះដោយការជួញដូរទាមទារឱ្យមានសេវាកម្មជាច្រើន នៅតាមតំណាក់កាលផ្សេងៗ នៃដំណើរការនៃការ ជួញដូរ : ពីមណ្ឌលសុវត្ថិភាព ការប្រឹក្សាចិត្តសាស្ត្រសង្គម ការថែទាំវេជ្ជសាស្ត្រ សេវាផ្នែកច្បាប់។ល។ ពួកគេក៏ប្រឈមនឹងបញ្ហា នៅពេលដែលពួកគេព្យាយាមធ្វើសមាហរណកម្មទៅក្នុងគ្រួសារ និងភូមិរបស់គេវិញដែលអាចមិនយល់ ពីឥទ្ធិពលអវិជ្ជមាននៃបទពិសោធន៍របស់ពួកគេ និង មានបំណងស្តីបន្ទោសដល់ជនរងគ្រោះ។ សេវាគាំទ្រទាំងនេះ ភាគច្រើនត្រូវបានផ្តល់ឱ្យដោយអង្គការមិនមែនរដ្ឋាភិបាលជាតិ និង អន្តរជាតិ។

## III. ការបង្ហាញទិន្នន័យ

### ការរំលោភ

ករណីទាំងឡាយដែលបានផ្តល់ឱ្យអ៊ិកផាតសម្រាប់គម្រោងទិន្នន័យរួមទាំង២៤០ករណី នៅក្នុងឆ្នាំ២០០៤ និង ៣១៨ករណី នៅក្នុងឆ្នាំ២០០៣ នៅក្នុង២០ និង ២១ខេត្តក្រុង។ *សូមមើលតួលេខ ២.០។* វាមិនមានន័យថាមានការថយចុះ នៅក្នុងឧប្បត្តិហេតុនៃការរំលោភក្នុងឆ្នាំ២០០៤ ពីឆ្នាំ២០០៣ ប៉ុន្តែការថយចុះនេះបញ្ជាក់ពីការថយចុះនូវ ករណីទាំងឡាយដែលរាយការណ៍ដោយក្រុមដៃគូរមកដល់អ៊ិកផាតសម្រាប់គោលបំណងនៃគម្រោងនេះ។

**តួលេខ ២. ករណីរំលោភដែលបានផ្តល់ក្នុងកំឡុងពេល**




តួលេខប្រចាំឆ្នាំខាងលើ ត្រូវបានគេបំបែកបន្ថែមតាមខេត្ត-ក្រុងដែលបង្ហាញថាការរំលោភ គឺមិននៅដាច់តែឯង សម្រាប់តំបន់ជាក់លាក់នោះទេប៉ុន្តែវាកើតនៅគ្រប់ទិសទីក្នុងប្រទេស។ ករណីរំលោភត្រូវបានគេរាយការណ៍ នៅក្នុងខេត្តចំនួន២០ នៅក្នុងឆ្នាំ២០០៣ និង២០ខេត្តក្នុងឆ្នាំ២០០៤ មានខេត្តស្ទឹងត្រែងក្នុងឆ្នាំ២០០៣ ដែលជំនួស ដោយខេត្តព្រះវិហារក្នុងឆ្នាំ២០០៤។ *មើលតួលេខ ៣.០ និង៤.០។* ទោះបីជាទីកន្លែងមួយចំនួនមានតួលេខខ្ពស់ជាងកន្លែងផ្សេងទៀត ប៉ុន្តែវាមិនបានឆ្លុះបញ្ចាំងនូវឧបទ្ទវហេតុកើនខ្ពស់ក្នុងតំបន់ទាំងនោះទេ ប៉ុន្តែវាបញ្ជាក់ច្បាស់ពីទីកន្លែងនៃ កម្មវិធីរបស់អង្គការនានាដែលបានចូលរួមនិងលទ្ធភាពនៃការឈានទៅដល់តំបន់ជុំវិញរបស់ពួកគេ។

## តួលេខ ៣. ការរំលោភតាមខេត្តឆ្នាំ២០០៤




## តួលេខ ៤. ករណីរំលោភតាមខេត្តឆ្នាំ២០០៣




ប៉ុន្តែអ្វីដែលគួរជាទីចាប់អារម្មណ៍នោះគឺការកើន ឬថយចុះនៃចំនួនករណីរំលោភតាមខេត្តនីមួយៗ នៅ ចន្លោះពេលពីរឆ្នាំ។ ប្រសិនបើករណីសរុបត្រូវបានរាយការណ៍ថា ថយចុះពីឆ្នាំ២០០៣ ទៅឆ្នាំ២០០៤ នោះ គំរូដូចគ្នានេះគួរតែត្រូវបានគេសង្កេតសម្រាប់ខេត្តនិមួយៗ ដោយសន្មតថា កម្មវិធីរបស់អង្គការនានាដែលផ្តល់សេវាកម្មទៅ អោយជនរងគ្រោះស្ថិតនៅក្នុងទីតាំងដដែល។ ទោះបីជា នៅឆ្នាំ២០០៣ មានករណីត្រូវបានគេរាយការណ៍ច្រើនជាងនៅឆ្នាំ២០០៤ក៏ដោយក៏ខេត្តបន្ទាយមានជ័យ និង ប៉ៃលិនត្រូវបានជាប់ជាខេត្តដែល មានចំនួនករណីច្រើននៅក្នុងឆ្នាំ ២០០៤ ខណៈដែលខេត្តកំពត និង ខេត្តកោះកុងពុំមានការប្រែប្រួលតួលេខនោះទេ។ លើសពីនេះទៀត មានសេចក្តីរាយការណ៍មួយត្រូវបានធ្វើឡើងនៅខេត្តព្រះវិហារ ដែលសម្រាប់ឆ្នាំមុនពុំមាន ករណីរំលោភសេពសន្ថវៈកើតឡើងនៅទីនោះទេ។ ផ្ទុយមកវិញពុំ

មានករណីរំលោភសេពសន្ថវៈណាមួយត្រូវបានគេ រាយការណ៍នៅឆ្នាំ ២០០៤ សម្រាប់ខេត្តស្ទឹងត្រែង ដែលនៅឆ្នាំមុនខេត្តនេះមានមួយករណី។ *មើលតួលេខ ៥. និង ៦.* កត្តាជាក់លាក់ដែលនាំឱ្យមានភាពខុសគ្នាទាំងនេះគួរតែត្រូវបានគេស៊ើបអង្កេតបន្ថែម ដើម្បីឱ្យបានដឹងពីលក្ខខ័ណ្ឌទូទៅ ដែលរួមចំណែកក្នុងការកើន ឡើងនៃសេចក្តីរាយការណ៍ពីបទឧក្រិដ្ឋនេះ (ឧទាហរណ៍ មានកម្មវិធីលើកកំពស់ចំណេះដឹងច្រើនរបស់អង្គការ និងអ្នកពាក់ព័ន្ធផ្សេងទៀត) ឬ ក៏លក្ខខ័ណ្ឌដែលនាំអោយមាននូវបទឧក្រិដ្ឋ (ការអភិវឌ្ឍន៍ឆាប់រហ័ស និង ការផ្លាស់ប្តូរទីលំនៅកាន់តែខ្ពស់)។

**តួលេខ ៥. ករណីរំលោភសេពសន្ថវៈចែកតាមខេត្ត សម្រាប់១១ ខេត្តនៃឆ្នាំ ២០០៣-២០០៤ (ផ្នែកទី ១)**




**តួលេខ ៦. ករណីរំលោភសេពសន្ថវៈចែកតាមខេត្ត សម្រាប់១០ ខេត្តនៃឆ្នាំ ២០០៣-២០០៤ (ផ្នែកទី ២)**




អំពើរំលោភសេពសន្ថវៈគឺជាអំពើហិង្សា។ នៅក្នុងករណីទាំងអស់ដែលទទួលបាន មានលក្ខណៈសម្គាល់ពីរជាក់លាក់ ដែលអាចជួយបង្ហាញឱ្យឃើញនូវបញ្ហានេះ។ លក្ខណៈសម្គាល់មួយគឺការកើនឡើងជាទូទៅនៅក្នុងប្រព័ន្ធ ផ្សព្វផ្សាយនូវការរំលោភបូក ឬ ការរំលោភដែលមានការចូលរួម ដោយជនល្មើសលើសពីម្នាក់។ ព័ត៌មានប្រៀបធៀបបានបង្ហាញ ឱ្យឃើញ

ថា ទោះបីជាករណីភាគច្រើនមានជនល្មើសតែម្នាក់ ប៉ុន្តែក៏មានការកើនឡើងបន្តិចផងដែរនូវករណីដែល បានប្រព្រឹត្តដោយមនុស្សច្រើននាក់ នៅក្នុងឆ្នាំ២០០៤ ធៀបទៅនឹងឆ្នាំមុន។ *មើលតារាង ៣.០* នេះអាចបង្ហាញ នូវទម្រង់ខ្លះៗនៃការធ្វើផែនការ និង ការសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងរបស់អ្នកចូលរួមពាក់ព័ន្ធ និង បង្ហាញ កាន់តែច្បាស់ថាការរំលោភគឺជាញឹកញាប់មានការរៀបចំគម្រោងជាមុន។ ទំហំទិន្នន័យពេលនេះ អាចមិនគ្រប់ គ្រាន់នឹងកំណត់បាននូវបញ្ហា ថាប្រសិនបើនេះ នឹងក្លាយជានិន្នាការមួយជាការពិត ដូចនេះវាមានសារសំខាន់ណាស់ថាការ យកចិត្តទុកដាក់បន្ថែមទៀតក្នុងការចងក្រងឯកសារករណី ព័ត៌មានដែលទទួលបាន អោយកាន់តែសុក្រិតពិតប្រាកដ និង ប្រយ័ត្នប្រយែងនៅឆ្នាំក្រោយៗមកទៀត។

**តារាង ៣ ចំនួននៃជនល្មើស**

| **ចំនួនជនល្មើស** | **២០០៣** | **២០០៤** |
|---|---|---|
| ១ | ២៤៣ ( ៩៥.៧% ) | ១៩២ ( ៩៥.៥% ) |
| ២-៧ | ១១ ( ៤.៣% ) | ៩ ( ៤.៥% ) |
| **សរុប** | **២៥៤ ( ១០០% )** | **២០១ ( ១០០% )** |

ទោះបីជាមានកង្វះខាតដូចគ្នានេះ ទាក់ទងនឹងព័ត៌មានស្តីពីការប្រើប្រាស់អាវុធ ក៏នៅតែអាចបញ្ជាក់បាននូវកំណើន នៃការប្រើប្រាស់អាវុធដូចជាពូថៅ កាំភ្លើងជាដើម ដែលកើនឡើង៥០% នៅឆ្នាំ២០០៤ ធៀបនឹងឆ្នាំ២០០៣។ អំពើហិង្សាទាំងនេះត្រូវបានមើលឃើញនៅក្នុងបរិបទទូទៅនៅក្នុងសង្គមកម្ពុជា និង ថាតើវាបន្តអនុញ្ញាត ឬ ពង្រឹងនូវឥរិយាបថនោះថាជាការបញ្ជាក់ពីភាពជាមនុស្សប្រុស ការប្រើប្រាស់អំណាច ឬ ជាមធ្យោបាយនៃការបញ្ជាក់ពីការមិនយល់ព្រម។

ការអនុវត្តច្បាប់នៅកម្ពុជាទាមទារឱ្យមានលិខិតបញ្ជាក់ពីគ្រូពេទ្យ ដើម្បីជួយបង្ហាញថាជនរងគ្រោះត្រូវបានរំលោភ និង ក៏ជាមធ្យោបាយមួយដើម្បីដាក់បន្ទុកប្រឆាំងនឹងជនជាប់ចោទ។ ហេតុដូចនេះហើយ វាមានសារសំខាន់ណាស់ថាការត្រួតពិនិត្យខាងវេជ្ជសាស្ត្រទាក់ទងទៅនឹងឯកសារនៃបណ្តឹងត្រូវធ្វើឱ្យបានឆាប់រហ័សជាទីបំផុត ដើម្បីចងក្រងឯកសារភស្តុតាងរូបសាស្ត្រនៃការរំលោភ។ គម្លាតកាន់តែវែងរវាងពេលវេលាដែលបទល្មើសបានកើតឡើងនិង ពេលវេលារាយការណ៍ធ្វើអោយករណីកាន់តែខ្សោយ (ពិបាកដោះស្រាយ)។ លើសពីនេះទៀត មានតែលិខិតបញ្ជាក់ របស់គ្រូពេទ្យនៅមន្ទីរពេទ្យធំៗភាគច្រើននៅទីរួមខេត្តទេ ដែលអាចទទួលយកបានដោយតុលាការ ដូចនេះដើម្បី ឱ្យជនរងគ្រោះរៀបចំបណ្តឹងដោយមានភ្ជាប់នូវឯកសារចាំបាច់ទាំងនោះ ពួកគេត្រូវធ្វើដំណើរទៅទីប្រជុំជនក្នុងទីរួមខេត្តដែលត្រូវចំណាយថវិកា និង ពេលវេលា ដែលជនរងគ្រោះភាគច្រើនមកពីទីជនបទដាច់ស្រយាលពុំមានលទ្ធភាពធ្វើបាន។ ការសម្រេចចិត្តក្នុងការរៀបចំពាក្យបណ្តឹងប្រឆាំងនឹងជនល្មើសមិនងាយស្រួលនោះទេ ហើយនេះអាច បង្ហាញឱ្យឃើញនូវរយៈពេលយូរមួយដែល ជនរងគ្រោះត្រូវរាយការណ៍អំពីករណីរំលោភ។ មានជនរងគ្រោះបន្តិច បន្តួចប៉ុណ្ណោះបានរាយការណ៍ពីបទល្មើសក្នុងរយៈពេលតិចជាងមួយសប្តាហ៍បន្ទាប់ពីត្រូវបានគេរំលោភ។ នៅឆ្នាំ ២០០៣ មានតែ ៨.៧% ប៉ុណ្ណោះបានរាយការណ៍ទៅដល់អង្គការក្នុងរយៈពេលនោះ។ ភាគច្រើននៃជនរងគ្រោះបានរៀប ចំពាក្យបណ្តឹងក្នុងរយៈពេលពីមួយសប្តាហ៍ឡើងទៅដល់១៩០សប្តាហ៍ក្រោយពីការរំលោភ។

ទោះជាយ៉ាងណាក៏ដោយ នៅឆ្នាំ២០០៤ ស្ថានភាពនេះមានការប្រសើរឡើងគួរអោយកត់សម្គាល់។ មានការកើនឡើងគួរឱ្យចាប់អារម្មណ៍នៃចំនួនករណីដែលបានរាយការណ៍កាន់តែឆាប់រហ័សក្រោយពីពេលកើតហេតុ។ ចាប់ពី ៨.៧% នៃចំនួនជនរងគ្រោះដែលបានរាយការណ៍ពីការរំលោភទៅអង្គការភ្លាមៗ (ក្នុងចន្លោះពេលតិចជាងមួយសប្តាហ៍) បានកើនឡើងដល់១៥%។ *មើលតារាង ៤.០* នេះអាចឱ្យយើងឃើញពីលទ្ធផលនៃកម្មវិធីរបស់ អង្គការដែលធ្វើការលើកកម្ពស់ការយល់ដឹងពីសិទ្ធិកុមារ និង ស្ត្រី និងបញ្ជាក់ថា ការរំលោភគឺជា បទឧក្រិដ្ឋដែលចាំបាច់ត្រូវតែរាយការណ៍ទៅសមត្ថកិច្ច។

ទោះបីជាជនរងគ្រោះកាន់តែច្រើនឡើងមានបំណងរាយការណ៍ករណីរំលោភទៅអង្គការ ពួកគេនៅតែពុំមានបំណងរាយការណ៍ករណីនេះទៅប៉ូលិសទេ។ ព័ត៌មានដែលបានទទួលពីមូលដ្ឋានទិន្នន័យ ដែលចាំបាច់ឱ្យមានការស៊ើបអង្កេតបន្ថែមទៀត បានបង្ហាញឱ្យឃើញថាមានសេចក្តីរាយការណ៍តិចតួចប៉ុណ្ណោះទៅប៉ូលិស។

**តារាង ៤. គម្លាតរវាងពេលកើតហេតុ និង ពេលរាយការណ៍ទៅអង្គការ**

| ចំនួនសប្តាហ៍ | ២០០៣ | ២០០៤ |
|---|---|---|
| តិចជាង ១ សប្តាហ៍ (ភ្លាមៗ) | ១១ (៨.៧%) | ១៤ (១៥%) |
| ១-៤ សប្តាហ៍ | ៤១ (៣២.៥%) | ៤៦ (៥៦%) |
| ៥-៨ សប្តាហ៍ | ១៤ (១១%) | ៧ (៧%) |
| ១៣-១៥០ សប្តាហ៍ | ៥៤ (៤៣%) | ២១ (២២%) |

ហេតុផលមួយក្នុងចំណោមហេតុផលចំបងជាច្រើនសម្រាប់ការមិនរាយការណ៍ពីករណីរំលោភ គឺ បរិយាកាសនិទណ្ឌភាពដែលមានសព្វថ្ងៃនេះ។ ទោះបីជាជនល្មើសត្រូវបានចោទប្រកាន់ ក៏វាងាយស្រួលសម្រាប់ពួកគេបញ្ចៀសខ្លួនពីការចោទប្រកាន់តាមរយៈការទូទាត់សំណងហិរញ្ញវត្ថុ ឬ សំណងផ្សេងៗទៀត។ វាសំខាន់ណាស់ក្នុងការកត់សម្គាល់ថា ខណៈពេលដែលជនល្មើសភាគច្រើនត្រូវបានចាប់ខ្លួន ៨៣.៦% នៅក្នុងឆ្នាំ ២០០៣ និង ៨០.៨%នៅក្នុងឆ្នាំ ២០០៤ មានចំនួនជនល្មើសតិចតួចបំផុតដែលត្រូវបានកាត់ទោស។ *មើលតារាង ៥.០ និង ៦.០* ភាពជាក់ស្តែងនេះបានបន្ទុចបង្អាក់ ជនរងគ្រោះមិនឱ្យប្តឹងប្រឆាំងនឹងជនល្មើស ដោយគេដឹងប្រាកដថាករណីនេះនឹងមិនប្រក្រតី ឬ ថាជនល្មើសនឹងមិនត្រូវទទួលទោស ប៉ុន្តែធ្វើឱ្យមានភាពអាម៉ាស់ដល់ក្រុមគ្រួសារទៅវិញ។

**តារាង ៥. ជនល្មើសដែលត្រូវបានចាប់ខ្លួន**

| | ២០០៣ (៣១៨) | ២០០៤ (២៤០) |
|---|---|---|
| ត្រូវបានចាប់ខ្លួន | ២៦៦ (៨៣.៦%) | ១៩៤ (៨០.៨%) |
| មិនត្រូវបានចាប់ខ្លួន | ៥២ (១៦.៤%) | ៤៦ (១៩.២%) |

**តារាង ៦. ជនល្មើសដែលត្រូវបានកាត់ទោស**

| | ២០០៣ (៣១៨) | ២០០៤ (២៤០) |
|---|---|---|
| មិនត្រូវបានកាត់ទោស | ២៩១ (៩១.៥%) | ២០៩ (៨៧%) |
| ត្រូវបានកាត់ទោស | ២៧ (៨.៥%) | ៣១ (១៣%) |

ជាញឹកញាប់វាក៏មានលេចឮផងដែរថាកុមារា និង បុរសត្រូវបានគេរំលោភ។ វាជាការពិត ប៉ុន្តែវាពិតជាងនេះទៅទៀត ដែល ថាជនរងគ្រោះភាគច្រើនលើសលុបគឺជាកុមារី និងស្ត្រី។ ខណៈដែលអាចមានបុរសខ្លះ ត្រូវបានគេរំលោភពួកគេ គ្រាន់តែតំណាងឱ្យតួលេខតូចមួយប៉ុណ្ណោះ ដូចដែលមាននៅក្នុងទិន្នន័យខាងក្រោមគឺ ៤%នៅឆ្នាំ ២០០៣ និង ១% នៅ ឆ្នាំ ២០០៤។ ប្រហែលវាជារឿងដែលគួរឱ្យខ្មាសគេជាងនេះទៅទៀតសម្រាប់កុមារារាយការណ៍ ថាខ្លួនត្រូវបានគេរំលោភ។ មានជនរងគ្រោះសញ្ជាតិផ្សេងៗទៀតផងដែរដែលត្រូវបានរំលោភនៅកម្ពុជា ដែលមាន ១% នៃជនរងគ្រោះសរុបនៅ ឆ្នាំ២០០៣ និង ១%នៅឆ្នាំ២០០៤។ *មើលតារាង ៧.០ និង ៨.០*។

ទោះបីជាបុរស និង ជនបរទេសមានចំណែកតិចតួចប៉ុណ្ណោះធៀបទៅនឹងចំនួនសរុបក៏ពិតមែន ក៏បទពិសោធន៍របស់ពួក គេដែលមិនគួរគិតថាមិនសំខាន់នោះទេ ពីព្រោះព័ត៌មានអាចត្រូវបានប្រើជាពិសេសនៅពេលបង្កើតកម្មវិធីសម្រាប់ជនរង គ្រោះ។

**តារាង ៧. ភេទនៃជនរងគ្រោះដោយការរំលោភសេពសន្ថវៈ**

| ភេទ | ២០០៣ | ២០០៤ |
|---|---|---|
| ស្ត្រី | ៣០៥ (៩៦%) | ២៣៧ (៩៩%) |
| បុរស | ១៣ (៤%) | ៣ (១%) |
| **សរុប** | **៣១៨ (១០០%)** | **២៤០ (១០០%)** |

**តារាង ៨. សញ្ជាតិនៃជនរងគ្រោះដោយការរំលោភសេពសន្ថវៈ**

| | ២០០៣ | ២០០៤ |
|---|---|---|
| ខ្មែរ | ៤៤៨ (៩៩%) | ១៨៨ (៩៩%) |
| មិនមែនខ្មែរ | ៤ (១%) | ២ (១%) |
| **សរុប** | **៤៥២ (១០០%)** | **១៩០ (១០០%)** |

មានគំនិត និង ការសន្មត់ជាច្រើនដែលថាមូលហេតុ និង គោលដៅនៃការរំលោភ ភាគច្រើនគឺជាការទទួលខុសត្រូវផ្ទាល់ របស់ជនរងគ្រោះតែម្តង។ ជារឿយៗ វាត្រូវបានគិតថាមានតែស្ត្រីក្មេង នៅលីវ មានភាពទាក់ទាញ និង ក្រមុំព្រហ្មចារីយ៍ ប៉ុណ្ណោះ ដែលអាចត្រូវបានគេរំលោភ។ ទោះជាយ៉ាងណាក៏ដោយ ទិន្នន័យប្រៀបធៀបបង្ហាញថា ស្ត្រីគ្រប់គ្នា មិនថា ឡើយអាយុ និង ស្ថានភាពគ្រួសារ (នៅលីវ ឬ រៀបការរួច)គឺងាយនឹងរងគ្រោះដោយការរំលោភ។ មានស្ត្រីនៅគ្រប់ អាយុទាំង អស់ជាជនរងគ្រោះនៃអំពើរំលោភសេពសន្ថវៈសម្រាប់រយៈពេលពីរឆ្នាំនេះ។ ទោះបីជាជនរងគ្រោះភាគច្រើន មានវ័យក្មេងក៏ពិតមែន ស្ត្រីចំណាស់ក៏មិនត្រូវបានលើកលែងដែរ។ ៨០.៧% នៃជនរង គ្រោះគឺជាកុមារ ឬអ្នកដែលមាន អាយុក្រោម១៨ឆ្នាំ ប៉ុន្តែភាគច្រើនគឺមានអាយុពី១៣-១៧ ឆ្នាំ។ មិនត្រឹមតែប៉ុណ្ណោះ សូម្បីកុមារអាយុ១ឆ្នាំ ក៏មិនរួច ខ្លួនដែរ។ ដូចគ្នានេះដែរស្ត្រីចំណាស់អាយុពី ៤១ ដល់ ៥៦ឆ្នាំ ដែលរៀបការហើយ និង មេម៉ាយ ក៏ជាគោលដៅនៃការ ចាប់រំលោភផងដែរ។ *មើលតារាង ៩.០ និង ១០.០*

បន្ថែមលើសពីនេះទៀត ករណីដែលបានទទួលក៏បានបង្ហាញផងដែរនូវនិន្នាការដែលគួរឱ្យបារម្ភផងដែរ។ កំណើននៃចំនួនស្ត្រីដែលមានវ័យកាន់តែក្មេងទៅ ត្រូវបានរំលោភនៅឆ្នាំ ២០០៤ ធៀបទៅនឹងឆ្នាំមុន ដោយកើនឡើងពី ៧.២% ទៅ ៩.២% សម្រាប់ ក្រុមអាយុ ១-៦ឆ្នាំ និង កំណើនពី ២៣.៦% ទៅ ២៤.៦% សម្រាប់ក្រុមអាយុ ៧-១២ឆ្នាំ។

**តារាង ៩. អាយុរបស់ជនរងគ្រោះ**

| ចន្លោះអាយុ | សរុបរយៈពេល២ឆ្នាំ | ២០០៣ | ២០០៤ |
|---|---|---|---|
| ១-៦ ឆ្នាំ | ៤៥ (៨.១%) | ២៣ (៧.២%) | ២២ (៩.២%) |
| ៧-១២ ឆ្នាំ | ១៣៤ (២៤.០%) | ៧៥ (២៣.៦%) | ៥៩ (២៤.៦%) |
| ១៣-១៧ ឆ្នាំ | ២៧១ (៤៨.៦%) | ១៥៦ (៤៩.១%) | ១១៥ (៤៧.៩%) |
| ១៨-៤០ ឆ្នាំ | ១០៥ (១៨.៨%) | ៦១ (១៩.២%) | ៤៤ (១៨.៣%) |
| ៤១-៥៦ ឆ្នាំ | ៣ (០.៥%) | ៣ (០.៩%) | ០ (០.០%) |
| **សរុប** | **៥៥៨ (១០០.០%)** | **៣១៨ (១០០.០%)** | **២៤០ (១០០.០%)** |

**តារាង១០. ស្ថានភាពគ្រួសារនៃជនរងគ្រោះដោយការរំលោភសេពសន្ថវៈ**

| ស្ថានភាពគ្រួសារ | ២០០៣ | ២០០៤ |
|---|---|---|
| នៅលីវ | ៣១៥ (៩៩%) | ២៣៧ (៩៨.៧%) |
| រៀបការរួច | ២ (០.៧%) | ៣ (១.៣%) |
| មេម៉ាយ | ១ (០.៣%) | ០ |

ទិន្នន័យក៏បានបង្ហាញផងដែរថាជនរងគ្រោះភាគច្រើនលើសលប់មានកម្រិតវប្បធម៌ទាបបំផុតដែលមានតែ១២.៥% ប៉ុណ្ណោះ ដែលបានរៀនដល់កម្រិតអនុវិទ្យាល័យនៅឆ្នាំ ២០០៣ និង ១.៦%នៅឆ្នាំ ២០០៤។ *មើលតារាង ១១.០*

**តារាង ១១. កម្រិតវប្បធម៌របស់ជនរងគ្រោះដោយការរំលោភសេពសន្ថវៈ**

| កម្រិតសិក្សា | ២០០៣ (៤០) | ២០០៤ (៦៣) |
|---|---|---|
| ពុំបានទទួលការសិក្សា | ៣ (៧.៥%) | ១ (១.៦%) |
| បឋមសិក្សា | ៣២ (៨០%) | ៦១ (៩៦.៨%) |
| អនុវិទ្យាល័យ | ៥ (១២.៥%) | ១ (១.៦%) |
| សរុប | ១០០% | ១០០% |

ខណៈដែលជនរងគ្រោះដោយការរំលោភភាគច្រើនជាស្ត្រី ប៉ុន្តែជនល្មើសភាគច្រើនគឺជាបុរស។ មានមួយរយ ភាគរយនៃជនល្មើសក្នុងអំពើរំលោភសេពសន្ថវៈដែលបានរាយការណ៍នៅក្នុងឆ្នាំ២០០៣ គឺជាមនុស្សប្រុសទាំងអស់ និង មាន ៩៩% នៅក្នុងឆ្នាំ ២០០៤។ ជនល្មើសជាស្ត្រីដែលមានក្នុងករណីរំលោភក្នុងឆ្នាំ២០០៤ គឺបានរៀបអាពាហ៍ពិពាហ៍ជាមួយជនដៃដល់ ហើយគ្រាន់តែធ្វើជាអ្នកសមគំនិតប៉ុណ្ណោះ។ មានករណីមួយប្តីបានប្រាប់ឱ្យប្រពន្ធរបស់ ខ្លួនជួយចងក្មេងស្រី។ ករណីផ្សេងទៀត ប្រពន្ធដែលមានអាយុ ៧២ ឆ្នាំ បានធ្វើដំណើររួមជាមួយប្តីគាត់ទៅ ចំការជាមួយនឹងក្មេងស្រីពីរនាក់ ហើយ

ក្រោយមកក្មេងស្រីទាំងពីរត្រូវបានរំលោភ។ ក្នុងករណីទាំងពីរនេះ ស្ត្រីត្រូវបានទទួលទោសជាប់ពន្ធនាគារ។ *មើលតារាង ១២.០* ។ មិនមែនជនល្មើសនៃអំពើរំលោភទាំងអស់សុទ្ធតែជាជនជាតិខ្មែរ នោះទេ។ មាន ៣%នៃករណីសរុបនៅឆ្នាំ ២០០៣ និង ២០០៤ ត្រូវបានប្រព្រឹត្តឡើងដោយជនបរទេសដែលមាន សញ្ជាតិអាមេរិក អង់គ្លេស ហូឡង់ ឥណ្ឌូនេស៊ី ញូហ្ស៊ីលែន ថៃ និង វៀតណាម។ *មើលតារាង ១៣.០*

**តារាង ១២. ភេទនៃជនល្មើសរំលោភសេពសន្ថវៈ**

| ភេទ | ២០០៣ (២៧៩) | ២០០៤ (២១៣) |
|---|---|---|
| ស្ត្រី | ០ | ៣ (១.៤%) |
| បុរស | ២៧៩ (១០០%) | ២១០ (៩៨.៦%) |

**តារាង ១៣. សញ្ជាតិនៃជនល្មើសរំលោភសេពសន្ថវៈ**

| សញ្ជាតិ | ២០០៣ (២៤២) | ២០០៤ (១៨៦) |
|---|---|---|
| ខ្មែរ | ២៣៤ (៩៧%) | ១៨១ (៩៧%) |
| មិនមែនខ្មែរ | ៨ (៣%) | ៥ (៣%) |

ជនល្មើសមានគ្រប់អាយុទាំងអស់ ប៉ុន្តែរឿងជាក់ស្តែងមួយដែលគួរឱ្យបានរម្ភ និង ពញ្ញាក់អារម្មណ៍បំផុតនោះ គឺមានក្មេងប្រុសក្មេងៗបំផុតអាចប្រព្រឹត្តបទរំលោភផងដែរ។ នៅឆ្នាំ ២០០៣ មាន ១០.៥% នៃជនល្មើសដែលមាន អាយុពី ១៣-១៧ ឆ្នាំ។ តួលេខនេះបានកើនឡើងយ៉ាងច្រើនរហូតដល់ ១៧.១% នៅឆ្នាំ ២០០៤។ *មើលតារាង ១៤.០* នេះ គូសបញ្ជាក់ថានៅក្នុងពេលដែលមានអាយុតិចបំផុត ជនល្មើសទាំងនេះមិនដឹងថាអ្វីជាអាកប្បកិរិយា សមរម្យដែលអាចទទួលយកបាន (និង ស្របច្បាប់) ចំពោះមនុស្សដែលមានភេទផ្ទុយគ្នា និង គួរតែបញ្ជូននូវសញ្ញាដំណឹងនេះទៅឪពុកម្តាយ ប្រព័ន្ធអប់រំ និង ប្រព័ន្ធផ្សព្វផ្សាយទាំងអស់ អំពីតម្លៃ និង អត្តចរិតដែលពួកគេព្យាយាមចែករំលែកទៅឱ្យ ក្មេងប្រុសៗ។ បុរសចំណាស់អាយុ ៤០ឡើងទៅ ដែលជាធម្មតាគឺជាឪពុក និង ជីតារបស់គេត្រូវបានរកឃើញ ផងដែរថាជនល្មើស មិនមែនមានភាគរយតិចតួចនោះទេ។

**តារាង ១៤. អាយុនៃអ្នកប្រព្រឹត្តបទរំលោភសេពសន្ថវៈ**

| អាយុ | សរុបរយៈពេល ២ឆ្នាំ | ២០០៣ (២១០) | ២០០៤ (១៧៥) |
|---|---|---|---|
| ១០-១២ ឆ្នាំ | ១ (០.៣%) | ១ (០.៥%) | |
| ១៣-១៧ ឆ្នាំ | ៥២ (១៣.៥%) | ២២ (១០។៥%) | ៣០ (១៧.១%) |
| ១៨-២៣ ឆ្នាំ | ១១៣ (២៩.៤%) | ៦៦ (៣១.៤%) | ៤៧ (២៦.៩%) |
| ២៤-៤០ ឆ្នាំ | ១៤៤ (៣៧.៤%) | ៨០ (៣៨.១%) | ៦៤ (៣៦.៦%) |
| ៤១-៦០ ឆ្នាំ | ៥៤ (១៤.០%) | ២៧ (១២.៩%) | ២៧ (១៥.៤%) |
| ៦១-៨៤ ឆ្នាំ | ២១ (៥.៥%) | ១៤ (៦.៧%) | ៧ (៤.០%) |
| សរុប | ៣៨៥ (១០០%) | ២១០ (១០០%) | ១៧៥ (១០០%) |

ដើម្បីទប់ស្កាត់ការរំលោភ ក្មេងស្រីជារឿយៗត្រូវបានហាមប្រាមមិនឱ្យដើរទៅកន្លែងដែលមិនស្គាល់ ឬ និយាយជាមួយជនដែលមិនស្គាល់ច្បាស់។ ទោះជាយ៉ាងណាក៏ដោយ កំណត់សម្គាល់រួមដែលបញ្ជាក់ថាករណីរំលោភត្រូវបាន ប្រព្រឹត្តដោយជនចម្លែកមិនស្គាល់មុខនោះមិនត្រូវបានរកឃើញនូវអំណះអំណាងដោយទិន្នន័យរបស់យើងនោះទេ ប៉ុន្តែវាបែរជាបង្ហាញនូវលក្ខណៈផ្ទុយទៅវិញ។ មានចំនួនករណីតិចតួចបំផុតដែលបានប្រព្រឹត្តដោយជនចម្លែក។ នៅឆ្នាំ២០០៣ មាន ៣៣% នៃករណីដែលបានរាយការណ៍គឺត្រូវបានប្រព្រឹត្តដោយសមាជិកគ្រួសារ ដែលនៅ ឆ្នាំ២០០៤ វាកើនឡើងបន្តិចដល់ ៣៤.៦%។ ក្រៅពីក្រុមគ្រួសារ ភាគច្រើននៃករណីរំលោភត្រូវបានប្រព្រឹត្តដោយ មនុស្សដែលស្គាល់គ្នាជាមួយជនរងគ្រោះដូចជាអ្នកស្គាល់គ្នា ឬ អ្នកជិតខាង។ *មើលតារាង ១៥.០*

ព័ត៌មានលម្អិតបន្ថែមអំពីអត្តសញ្ញាណរបស់ជនល្មើសគឺប្រវត្តិមុខរបររបស់ពួកគេ។ ខណៈដែលភាគច្រើនជាជន ស៊ីវិលក៏មានចំនួនករណីសំខាន់ៗដែលប្រព្រឹត្តដោយទាហាន និង ប៉ូលិស ក៏ដូចជាមន្ត្រីរាជការរបស់រដ្ឋាភិបាល។ នេះវាចាំបាច់ និងមានសារសំខាន់ណាស់ដើម្បីបញ្ជាក់ ពីព្រោះទាំងសមាជិកស៊ីវិល និង យោធារបស់រដ្ឋាភិបាល មានអាណត្តិរបស់គេក្នុងការលើកកំពស់ការអនុវត្តច្បាប់ និង ថែរក្សាសុខមាលភាពរបស់ប្រជាជន រួមទាំងជនរង គ្រោះផងដែរ។ ហេតុនេះ សម្រាប់ពួកគេដែលប្រព្រឹត្តបទរំលោភមិនត្រឹមតែជាបទឧក្រិដ្ឋទេ ប៉ុន្តែថែមទាំងជាការមិនបំពេញការងាររបស់ពួកគេទៀតផង។ *មើលតារាង ១៦.០* ក្នុងចំណោមជនល្មើសដែលជាជនស៊ីវិល មាន និសិត្ស ១០.៤% នៅឆ្នាំ ២០០៣ និង ៨.៨% នៅឆ្នាំ២០០៤ ដែលផ្តល់ជាសញ្ញាឱ្យមានតម្រូវការជាបន្ទាន់ដើម្បីត្រួត ពិនិត្យឡើងវិញនូវការទទួលខុសត្រូវនៃ ប្រព័ន្ធអប់រំទៅលើអាកប្បកិរិយារបស់សិស្ស។

**តារាង ១៥ ទំនាក់ទំនងរវាងអ្នកប្រព្រឹត្តនិងជនរងគ្រោះ**

| ទំនាក់ទំនងជាមួយជនរងគ្រោះ | ២០០៣ | ២០០៤ |
|---|---|---|
| គ្រួសារ (សាច់ជិត និង ឆ្ងាយ) | ៣៣ (៣៣%) | ៤៤ (៣៤.៦%) |
| អ្នកស្គាល់គ្នា អ្នកជិតខាង ម្ចាស់ផ្ទះ | ៥៧ (៥៣.៨%) | ៨០ (៦៣%) |
| អ្នកធ្វើការដែលមានឋានៈ (ក្រុមហ៊ុន/សាលារៀន) | ២ (២%) | ២ (១.៦%) |
| មិត្តភក្តិ | ៦ (៥.៦%) | ០ |
| ជនចម្លែក | ៦ (៥.៦%) | ១ (០.៨%) |

**តារាង១៦. មុខរបរ អ្នកប្រព្រឹត្តបទរំលោភ**

| មុខរបរ | ២០០៣ | ២០០៤ |
|---|---|---|
| ទាហាន / ប៉ូលិស / អង្គរក្ស (៤+៣/១) | ១១ (៨.៥%) | ៨ (៧.៣%) |
| បុគ្គលិករដ្ឋាភិបាលស៊ីវិល | ៣ (២.៣%) | ០ |
| មន្ត្រីរាជការ (ស៊ីវិល និង ឯកសណ្ឋាន) | ១១ (១១.៧%) | ៧ (៦.៤%) |
| ជនស៊ីវិល | ១១៥ (៨៩.២%) | ១០២ (៩២២.៧%) |

## ការជួញដូរ

ករណីជួញដូរ សរុបចំនួន៧៦១ករណី ដែលបានរាយការណ៍ដោយ អង្គការដៃគូចំនួន ១៩ សម្រាប់រយៈពេល២ឆ្នាំ ដែលមាន៣៩៣ករណីនៅឆ្នាំ ២០០៣ និង ៣៦៨ករណីនៅឆ្នាំ២០០៤។ *មើលតួលេខ ៧.០* ខណៈដែលតួលេខនេះបង្ហាញនូវការថយចុះក្នុងរយៈពេលពីរឆ្នាំ នេះមិនមែនមានន័យថាវាថយចុះនូវអំពើជួញដូរនោះទេ ប៉ុន្តែវាបានឆ្លុះបញ្ចាំងច្រើនជាងពីលទ្ធភាពកម្មវិធីរបស់អង្គការមិនមែនរដ្ឋាភិបាលជាដៃគូដែលបានទៅដល់។

**តួលេខ ៧. ករណីជួញដូរដែលបានទទួលសម្រាប់កំឡុងពេល**




ទិន្នន័យក៏បានបង្ហាញផងដែរថាការជួញដូរកើតឡើងស្ទើរតែនៅគ្រប់ខេត្ត។ ភាគច្រើនកើតនៅរាជធានីភ្នំពេញ និង ខេត្តជាប់ព្រំដែនគឺខេត្តបន្ទាយមានជ័យ ដែលនៅឆ្នាំ២០០៤ ភ្នំពេញមានចំនួនច្រើនជាងគេ និង នៅឆ្នាំ២០០៣ ខេត្តបន្ទាយមានជ័យមានចំនួនច្រើនជាងគេ។ *មើលតួលេខ ៨.០ និង ៩.០* ។ ដោយសារតែប្រជាជនដែលរស់នៅក្នុងខេត្តទាំងពីរនេះជាអ្នកផ្លាស់ប្តូរទីលំនៅផងដែរនោះ ពួកគេអាចមកពីតំបន់ផ្សេងៗនៃប្រទេសប្រហែលជាដើម្បីរកការងារធ្វើ។

**តួលេខ ៨. ការជួញដូរតាមខេត្ត ២០០៤**




**តួលេខ ៩. ការជួញដូរតាមខេត្ត ២០០៣**




ដូចជាករណីនៃការរំលោភសេពសន្ថវៈដែរ វាមិនមានលទ្ធភាពក្នុងការធ្វើការសន្និដ្ឋានទូទៅសម្រាប់ប្រទេសទាំងមូល ដោយចាត់ ថាខេត្តណាមួយដែលកើតករណីជួញដូរច្រើនជាងគេ មិនត្រឹមតែពុំមានតំណាងនៃករណីដែល បានរួមបញ្ចូលនោះទេ ប៉ុន្តែថែមទាំងមានភាពស្មុគស្មាញនៃដំណើរការនៃការជួញដូរថែមទៀតផង។ ទោះជាយ៉ាងណាក៏ដោយ អ្វីដែលសំខាន់នោះគឺមានការផ្លាស់ប្តូរនូវចំនួនករណីក្នុងចន្លោះពីឆ្នាំ ២០០៣-២០០៤ នៅតាមបណ្តាខេត្ត មួយចំនួន។ ទោះបីជាមានការថយចុះជាទូទៅនូវករណីដែលបានរាយការណ៍ពីឆ្នាំ ២០០៣ ទៅ ២០០៤ ក៏វាមានការកើនឡើងផងដែរសម្រាប់រាជធានីភ្នំពេញ ខេត្តព្រៃវែង សៀមរាប និង កំពង់ស្ពឺក្នុងរយៈពេលដូចគ្នានេះ។ *មើលតួលេខ ១០.០ និង ១១.០។*

គំរូផ្ទុយគ្នានេះតំរូវអោយមានការស៊ើបអង្កេតបន្ថែម ទៅលើស្ថានភាពអ្វីដែលបណ្តាលឱ្យមាននិន្នាការ ផ្ទុយគ្នាសម្រាប់ខេត្តផ្សេងៗទៀត ។

**តួលេខ ១០. ការជួញដូរក្នុងខេត្តនីមួយៗ ២០០៣-២០០៤, ១០ ខេត្ត (ផ្នែកទី១)**




**តួលេខ ១១. ការជួញដូរក្នុងខេត្តនីមួយៗ ២០០៣-២០០៤, ៩ ខេត្ត (ផ្នែកទី២)**




ករណីជួញដូរភាគច្រើនដែលបានរាយការណ៍ដោយអង្គការជាដៃគូ សម្រាប់ឆ្នាំ ២០០៣ និង ២០០៤ ជាករណីក្នុងស្រុក។ ទោះជាយ៉ាងណាក៏ដោយ មានករណីគួរអោយចាប់អារម្មណ៍មួយចំនួនបានជួញដូរទៅប្រទេសថៃ និង មួយចំនួនតូចទៅប្រទេសម៉ាឡេស៊ីផងដែរ។ មានចំណុចត្រួតពិនិត្យជាផ្លូវការពីរដែលចូលពីកម្ពុជាទៅថៃ គឺប៉ោយប៉ែត និង កោះកុង ហើយជារឿយៗ ពួកគេជួយសម្រួលក្នុងការបញ្ជូនមនុស្សរវាងប្រទេសទាំងពីរ។ ប័ណ្ណចូលទៅក្នុងប្រទេសថៃ នៅពេលថ្ងៃក៏ត្រូវបានគេចេញឱ្យប្រើប្រាស់ ដែលអាចធ្វើឱ្យជនកម្ពុជាជាច្រើនបានចូលទៅ ក្នុងគោលបំណងផ្សេងៗ រាប់ពីការធ្វើពាណិជ្ជកម្មរហូតដល់ការសុំទាន។ នៅឆ្នាំ ២០០៤ ប្រទេសវៀតណាម និង ប្រទេសចិនក៏ត្រូវបានកត់ត្រាថាជា ប្រទេសគោលដៅបន្ថែមផងដែរ។ *មើលតួលេខ ១២.០ និង ១៣.០*

គោលដៅនៃករណីជួញដូរក្នុងស្រុកមានច្រើនលើសលប់នៅទីក្រុងភ្នំពេញ និង ទីរួមខេត្តផ្សេងៗដូចជាក្រុងព្រះសីហនុ និង ខេត្តសៀមរាបដែលមានទេសចរណ៍ និង ឱកាសការងារ និង សេវាមូលដ្ឋានផ្សេងៗដែលទាក់ទងវិស័យនេះ។ *មើលតួលេខ ១៤.០ និង ១៥.០*

**តួលេខ ១២. គោលដៅនៃការជួញដូរតាមប្រទេស ២០០៣**




**តួលេខ ១៣. គោលដៅនៃការជួញដូរតាមប្រទេស ២០០៤**



## តួលេខ ១៤. គោលដៅនៃការជួញដូរតាមខេត្ត ២០០៣




## តួលេខ ១៥. គោលដៅនៃការជួញដូរតាមខេត្ត ២០០៤




ទោះបីជាច្បាប់បច្ចុប្បន្ននៅមានភាពមិនច្បាស់លាស់សម្រាប់ការជួញដូរ ក៏មានជនជាប់ចោទសម្រាប់ករណីទាំងអស់ ក្នុងឆ្នាំ ២០០៣ និង ៨៤.៦%នៃករណីនៅឆ្នាំ២០០៤ ត្រូវបានចោទប្រកាន់ពីបទជួញដូរ។ *មើលតារាង ១៧.០*

## តារាង១៧. ប្រភេទនៃការចោទប្រកាន់

| | **សរុបសម្រាប់រយៈពេល ២ឆ្នាំ** | **២០០៣** | **២០០៤** |
|---|---|---|---|
| ការជួញដូរ | ៤១ (៩១.១%) | ១៩ (១០០%) | ២២ (៨៤.៦%) |
| អនាចារ | ១ (២.២%) | | ១ (៣.៨%) |
| សញ្ជូរកម្ម | ៣ (៦.៧%) | | ៣ (១១.៥%) |
| **សរុប** | **៤៥ (១០០%)** | **១៩ (១០០%)** | **២៦ (១០០%)** |

**ជនរងគ្រោះ**

ប្រជាជនកម្ពុជាមិនមែនសុទ្ធតែជាអ្នកដែលត្រូវគេជួញដូរនៅកម្ពុជាទេ។ ជនជាតិវៀតណាមត្រូវបានរកឃើញថាមាន ១៣% ត្រូវបានជួញដូរនៅឆ្នាំ ២០០៣ និង ១៦% នៅឆ្នាំ ២០០៤ ជនរងគ្រោះមិនមានដើមកំណើតនៅប្រទេសវៀតណាមទាំងអស់នោះទេ ក៏មានខ្លះដែលមានទីលំនៅនៅប្រទេសកម្ពុជាស្រាប់ទៅហើយ។ មានតែ ៩% និង ៨% នៃជនរងគ្រោះក្នុងឆ្នាំ ២០០៣ និង ២០០៤ ដែលមកពីប្រទេសវៀតណាម។ *សូមមើលតារាង ១៨.០ និង តួលេខ ១៦.០* សម្រាប់តួលេខរួមគ្នា និង បែងចែកតាមឆ្នាំ។

**តារាង១៨. សញ្ជាតិជនរងគ្រោះដោយការជួញដូរ**

| | **២០០៣ (២៨៤)** | **២០០៤ (២៨៧)** |
|---|---|---|
| ខ្មែរ | ២៤៧ (៨៧.0%) | ២៤១ (៨៤.0%) |
| វៀតណាម | ៣៧ (១៣.0%) | ៤៦ (១៦.0%) |
| សរុប | ២៨៤ (១00%) | ២៨៧ (១00%) |

**តួលេខ ១៦. ប្រទេសកំណើតនៃជនរងគ្រោះដោយការជួញដូរ**




មានជំនឿជាទូទៅ ដែលថាប្រជាជនមកពីខេត្តក្រីក្រគឺជាជនដែលងាយទទួលរងគ្រោះដោយការជួញដូរជាងគេបំផុត តែពេលនេះបែរជាទិន្នន័យបានបង្ហាញថាភាគច្រើននៃជនរងគ្រោះមកពីទីក្រុងភ្នំពេញ និង តាមតំបន់មួយចំនួនដែលមានសេវាមូលដ្ឋានច្រើនជាងគេទៅវិញ។ នេះអាចមកពីមូលហេតុច្បាស់លាស់ថាទីក្រុងដូចជាភ្នំពេញគឺជាចំណុច ចាប់ផ្តើមសម្រាប់ពួកអ្នកជួញដូរ។ ជនទេសន្តប្រវេសន៍ជាច្រើនអាចត្រូវបានបោកបញ្ឆោតពីដំបូងដោយការផ្តល់ការងារសមស្របនៅទីនោះ ប៉ុន្តែទីបំផុតត្រូវធ្លាក់ក្នុងអន្ទាក់ដោយការសន្យាក្លែងក្លាយនៃឱកាសការងារដែលប្រសើរជាងនេះ នៅទីកន្លែងដដែល ឬកន្លែងផ្សេងទៀត។ បន្ទាប់មកជនរងគ្រោះត្រូវបានតាំងទីលំនៅនៅភ្នំពេញក្នុងនាម ជាជនផ្លាស់ទីលំនៅ ដើម្បីមូលហេតុសេដ្ឋកិច្ចមុនពេលត្រូវបានគេជួញដូរ។ *មើលតួលេខ ១៧.០*

**តួលេខ ១៧. ខេត្តកំណើតនៃជនរងគ្រោះដោយការជួញដូរ**




ឯកសារសំណេរជាច្រើនស្តីពីការជួញដូរនៅកម្ពុជា បានចង្អុលបង្ហាញនូវភាពជាក់ស្តែងថាទាំងបុរស និង ស្រ្តីត្រូវបានគេជួញដូរ។ នេះត្រូវបានបញ្ជាក់ដោយទិន្នន័យដែលប្រមូលបាន ទោះជាវាបង្ហាញថាមានស្រ្តីត្រូវបានគេ ជួញដូរច្រើនជាងបុរសក៏ដោយ។ *មើលតារាង ១៩.០* ចំនួនដែលជឿជាក់មួយនៃជនរងគ្រោះដោយការជួញដូរមាន អាយុក្រោម១៨ឆ្នាំ ៤០% សម្រាប់ឆ្នាំ២០០៣ និង ២៥%សម្រាប់ឆ្នាំ ២០០៤។ សូម្បីតែកុមារចន្លោះពី ៩-១២ឆ្នាំ ក៏ត្រូវបានគេជួញដូរផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ស្ថិតិក៏បានបង្ហាញផងដែរថាមានការថយចុះនៃចំនួនកុមារ និង បុរសដែលត្រូវគេជួញដូរពីឆ្នាំ ២០០៣ ទៅ ២០០៤។ *មើលតារាង ២០.០* ជនរងគ្រោះភាគច្រើនគឺជាអ្នក នៅលីវប៉ុន្តែក៏មានរួមបញ្ចូលផងដែរនូវអ្នកដែលបានរៀបការហើយ លែងលះ មេម៉ាយ និង ពោះម៉ាយ។ *មើល តារាង ២១.០* តួលេខទាំងនេះអាចឆ្លុះបញ្ចាំងផងដែរនូវគំរូនៃការផ្លាស់ទីលំនៅ ដែលត្រូវបានរាយការណ៍ថាកំពុងកើនឡើងនៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។

**តារាង១៩. ភេទនៃជនរងគ្រោះដោយការជួញដូរ**

| ភេទ | ២០០៣ (៣៩៣) | ២០០៤ (៣៦៨) |
|---|---|---|
| ស្រ្តី | ៣២៥ (៨២.៧%) | ៣៤៥ (៩៣.៨%) |
| បុរស | ៦៨ (១៧.៣%) | ២៣ (៦.៣%) |
| **សរុប** | **៣៩៣ (១០០%)** | **៣៦៨ (១០០%)** |

**តារាង២០. អាយុនៃជនរងគ្រោះដោយការជួញដូរ(ពីការចាប់ផ្តើម)**

| ចន្លោះអាយុ | ២០០៣ (៩០) | ២០០៤ (៨៨) |
|---|---|---|
| ៩-១២ ឆ្នាំ | ៦ (៦.៧%) | ២ (២.៣%) |
| ១៣-១៧ ឆ្នាំ | ៣០ (៣៣.៣%) | ២០ (២២.៧%) |
| ១៨-២៤ ឆ្នាំ | ៥០ (៥៥.៦%) | ៥៩ (៦៧.០%) |

| | | |
|---|---|---|
| ២៥-៣២ ឆ្នាំ | ៤ (៤.៤%) | ៧ (៨.០%) |
| **សរុប** | **៩០ (១០០%)** | **៨៨ (១០០%)** |

**តារាង២១. ស្ថានភាពគ្រួសារនៃជនរងគ្រោះដោយការជួញដូរ**

| ស្ថានភាពគ្រួសារ | ២០០៣ (៣៩៣) | ២០០៤ (៣៦៨) |
|---|---|---|
| នៅលីវ | ៣៧៧ (៩៥.៩%) | ៣៣៦ (៩១.៣%) |
| រៀបការ | ៨ (២.០%) | ១២ (៣.៣%) |
| មេម៉ាយ | ១ (០.៣%) | ៣ (០.៨%) |
| ពោះម៉ាយ | ១ (០.៣%) | ១ (០.៣%) |
| លែងលះ | ៦ (១.៥%) | ១៦ (៤.៣%) |
| **សរុប** | **៣៩៣ (១០០%)** | **៣៦៨ (១០០%)** |

ទិន្នន័យបានបង្ហាញថាអំពើជួញដូរត្រូវបានប្រព្រឹត្តឡើងដោយមនុស្សទាំងប្រុស ទាំងស្ត្រី ទោះបីថាវាមានស្ត្រីច្រើនជាងក៏ដោយ។ *មើលតារាង ២២.០* ។ អ្នកជួញដូរភាគច្រើនគឺមានទំនាក់ទំនងដោយផ្ទាល់ និង ដោយប្រយោលជាមួយឧស្សាហកម្មផ្លូវភេទដូចជាម្ចាស់បន ឈ្មួញកណ្តាល (មេមីង) របស់នារីរកស៊ីផ្លូវភេទ ខារ៉ាអូខេ និង ក្លឹបរាត្រី។ គួរឱ្យចាប់អារម្មណ៍ជាងនេះគឺមានការចូលរួមផងដែរពីសំណាក់ប៉ូលិស និងមន្ត្រីរាជការរបស់រដ្ឋាភិបាល ដែលគេជឿថាបានសម្រួលក្នុង ប្រតិបត្តិការផ្សេងៗដែលជាផ្នែកមួយនៃឧស្សាហកម្មផ្លូវភេទ។ *មើលតារាង ២៣.០* អ្នកជួញដូរផ្សេងៗទៀតមានជាអាទិ៍ ម្ចាស់ហាងកាហ្វេ អ្នកបើកបរ កម្មកររោងចក្រ អ្នកលក់បាយ អ្នករកស៊ីផ្លូវភេទ កសិករ អ្នកនេសាទ។ល។ ដែលយើងអាចនិយាយបានថា អ្នកជួញដូរអាចជានរណាម្នាក់ ដែលរស់នៅក្នុងសហគមន៍ជាមួយមនុស្សដែលជិតស្និទ្ធបំផុត។

**តារាង២២. ភេទនៃអ្នកជួញដូរ**

| ភេទ | ២០០៣ (៣០៨) | ២០០៤ (២៨៣) |
|---|---|---|
| ស្ត្រី | ២០២ (៦៥.៦%) | ១៧៨ (៦២.៩%) |
| បុរស | ១០៦ (៣៤.៤%) | ១០៥ (៣៧.១%) |
| **សរុប** | **៣០៨ (១០០)** | **២៨៣ (១០០%)** |

**តារាង២៣. មុខរបរនៃអ្នកជួញដូរ**

| មុខរបរ | ២០០៣ (១៩២) | ២០០៤ (២០៧) |
|---|---|---|
| ម្ចាស់បន មេអណ្តើត អ្នករកស៊ីផ្លូវភេទ | ១១៥ (៥៩.៩%) | ១៥២ (៧៣.៤%) |
| ខារ៉ាអូខេ និង ក្លឹបរាត្រី | ៩ (៤.៧%) | ៨ (៣.៩%) |
| បុគ្គលិករដ្ឋាភិបាល / ប៉ូលិស | ២ (១.០%) | ៥ (២.៤%) |
| ផ្សេងៗ | ៦៦ (៣៤.៤%) | ៤២ (២០.៣%) |
| **សរុប** | **១៩២ (១០០%)** | **២០៧ (១០០%)** |

ការជួញដូរគឺជាដំណើរការនៃការទាញចេញដែលចាប់ផ្តើមពីការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការសំចត ឬ ការទទួលជនរងគ្រោះ និងអាចទាមទារឱ្យមានភាគីច្រើនឈរជួរមុខ ឬ ធ្វើជាអ្នកសម្របសម្រួលកណ្តាល នៅ ដំណាក់កាលផ្សេងៗគ្នានៃប្រតិបត្តិការ។ ហេតុដូចនេះជនទាំងនេះដែលដើរតួជាអ្នកនៅមុខ ឬ អ្នកសម្របសម្រួល កណ្តាល ចាំបាច់ត្រូវតែមានភាពជិតស្និទ្ធ ដែលទទួលបាននូវសេចក្តីទុកចិត្តពីជនរងគ្រោះ។ ដោយសារតែមូលហេតុនេះហើយ មានការភ័ន្តច្រឡំជាញឹកញាប់ទៅលើអត្តសញ្ញាណរបស់អ្នកជួញដូរ ឬ អ្នកសម្របសម្រួល/ការីកណ្តាល។ ដូចនេះវាមិនគួរអោយភ្ញាក់ផ្អើលទេចំពោះករណីដែលទទួលបាននៅក្នុងគម្រោងនេះ បានគូសបញ្ជាក់ថាអ្នក ជួញដូរមានភាពជិតស្និទ្ធទៅនឹងជនរងគ្រោះ។ ឧទាហរណ៍ ៥៣.៣% នៃអ្នកជួញដូរដែលស្គាល់អត្តសញ្ញាណនៃឆ្នាំ ២០០៣ ជាសមាជិកគ្រួសារជិត ឬឆ្ងាយ ជាមួយជនរងគ្រោះ ហើយតួលេខនេះដល់ត្រឹម ៣៧.៣% នៅឆ្នាំ ២០០៤។ មានចំនួនអ្នកជួញដូរតិចតួចប៉ុណ្ណោះដែលជាអ្នកចម្លែក ឬជាមេបនស្រី ដែលមានតែ ៥.៣%នៅឆ្នាំ ២០០៣ និង ២៧% នៅឆ្នាំ ២០០៤ ។ *មើលតារាង ២៤.០* ។ ទោះបីជាតួលេខនេះត្រូវការចាំបាច់ក្នុងការផ្ទៀងផ្ទាត់តាមរយៈ មធ្យោបាយផ្សេងៗ អ្នកជួញដូរដែលជាសមាជិកគ្រួសារមានចំនួនចុះ ក្នុងឆ្នាំ ២០០៤ ហើយ កើនឡើងនៃអ្នក ជួញដូរដោយផ្ទាល់ពីឧស្សាហកម្មផ្លូវភេទ អាចផ្តល់នូវសញ្ញានៃការផ្លាស់ប្តូរលក្ខណៈនៃការជួញដូរឱ្យកាន់តែមាន លក្ខណៈតម្រង់ទិសទៅរកឧស្សាហកម្មផ្លូវភេទតែម្តង ឬក៏ គ្រាន់តែមានការកើនឡើងនៃការបើករបរអាជីវកម្ម ឬ ការ អាចរកបាននៃពេស្យាចារនៅតំបន់កំណើត។

**តារាង២៤. ទំនាក់ទំនងជាមួយជនរងគ្រោះ**

| ទំនាក់ទំនង | ២០០៣ (៧៥) | ២០០៤ (៥១) |
|---|---|---|
| សមាជិកគ្រួសារ | ៤០ (៥៣.៣%) | ១៩ (៣៧.៣%) |
| ទេសចរ និង អ្នកស្គាល់គ្នា | ១៤ (១៨.៧%) | ៧ (១៣.៧%) |
| មិត្តភក្តិ អ្នកជិតខាង | ១៧ (២២.៧%) | ១១ (២១.៦%) |
| ជនប្លែកមុខ ម្ចាស់បន | ៤ (៥.៣%) | ១៤ (២៧.៥%) |
| **សរុប** | **(១០០%)** | **(១០០%)** |

## IV. អនុសាសន៍

ករណីទាំងឡាយបានបង្ហាញថាកុមារនៅកម្ពុជាមិនត្រឹមតែមិនបានទទួលផលប្រយោជន៍ទាក់ទងនឹងវិស័យ អប់រំ និង សេដ្ឋកិច្ចប៉ុណ្ណោះទេ ថែមទាំងត្រូវប្រឈមមុខទៅនឹងការរំលោភបំពាន និង ការកេងប្រវ័ញ្ច។ ផលប៉ះពាល់នៃការមិនបានទទួលផលប្រយោជន៍នេះបានធ្វើឱ្យពួកគេក្លាយជាជនរងគ្រោះ និង / ឬ ជនល្មើសនៃអំពើ រំលោភ និង អំពើជួញដូរ។ លើសពីនេះទៀត មិនមែនកុមារកម្ពុជាទាំងអស់ ជួបនូវបញ្ហាទាំងនេះដូចគ្នានោះទេ។ ទិន្នន័យបង្ហាញថា មានក្មេងស្រីច្រើនជាងក្មេងប្រុស ដែលជាគោលដៅនៃអំពើរំលោភ និង ជួញដូរ។ ទិន្នន័យក៏បានបង្ហាញផងដែរថាតើក្មេងប្រុសប្រព្រឹត្តករណីរំលោភ សេពសន្ថវៈកើនឡើង និង ស្ត្រី វ័យក្មេងត្រូវបានគេ ប្រើដើម្បីជួយសម្រួល ក្នុងការជ្រើសរើសមនុស្សដែលអាចជាជនរងគ្រោះនៃការជួញដូរដោយរបៀបណា។

ជាទូទៅ តួនាទីកុមារនៅក្នុងសង្គមកម្ពុជាចាំបាច់ត្រូវកែលំអ។ សិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការអប់រំ សុខភាព និង សេរីភាពវៀរចាកពីការរំលោភបំពានផ្សេងៗត្រូវតែធានាដោយរដ្ឋមុនអ្វីៗទាំងអស់។ កុមារមិនគួរធ្វើការ ដើម្បីចិញ្ចឹម ឪពុកម្តាយរបស់ពួកគេទេ ប៉ុន្តែគួរតែត្រូវបានការឧត្តម្ភរហូតដល់ពួកគេក្លាយ ជាមនុស្សពេញវ័យ និង អាចរកបាននូវប្រាក់ ដើម្បីជីវិតរស់នៅសមរម្យមួយ។ រដ្ឋាភិបាលចាំបាច់ត្រូវតែដោះស្រាយបញ្ហាបន្ទាន់នេះ ពីពេលនេះតទៅ ដូច្នេះទៅអនាគត វានឹងមិនកាន់តែធ្ងន់ធ្ងរជាងនេះដែលអាចធ្វើឱ្យសមាសភាពអាយុរបស់ប្រជាជន នៅដដែលក្នុងរយៈពេល ៥ឆ្នាំទៀត។ នៅក្នុងបរិបទទូទៅ វិធានការច្បាស់លាស់ជាច្រើនគួរតែ ត្រូវបានអនុវត្ត ដើម្បីដោះស្រាយបញ្ហាការរំលោភបំពាន និង កេងប្រវ័ញ្ចផ្លូវភេទតាមរយៈការរំលោភ សេពសន្ថវៈ និង ជួញដូរផ្លូវភេទ។

ដោយសារភាគច្រើននៃជនរងគ្រោះនៃអំពើរំលោភសេពសន្ថវៈ និង ជួញដូរដែលបានរាយការណ៍ គឺជាស្រីក្មេងៗ នោះ កម្មវិធីរបស់រដ្ឋាភិបាលក៏ដូចជាអង្គការមិនមែនរដ្ឋាភិបាលគួរពិចារណាដល់បញ្ហានេះ ចំពោះខ្លឹមសារនៃសកម្មភាពលើក កម្ពស់មនសិការ គម្រោងបណ្តុះបណ្តាលផ្សេងៗ ការផ្តល់ប្រឹក្សា។ល។ សូម្បីតែបុគ្គលិកនៃកម្មវិធីដែលត្រូវផ្តល់សេវា ផ្សេងៗដល់ជនរងគ្រោះក៏ដោយ គួរតែធានាឱ្យបានថាពួកគេឆាប់យល់ច្បាស់ទៅនឹងតម្រូវការជាពិសេស របស់ជនរងគ្រោះ ដោយមិនត្រូវកាត់បន្ថយនូវតម្រូវការរបស់ក្រុមអាយុផ្សេងទៀត និង កុមារា។
ការរកឃើញថាជនល្មើសស្ទើរទាំងអស់ជាមនុស្សប្រុស និង មានអាយុកាន់តែក្មេងទៅៗគួរតែពញ្ញាក់ស្ថាប័នផ្សេងៗគ្នា ដែលទទួលខុសត្រូវក្នុងការអប់រំ និង ការបង្កើតគុណតម្លៃ (គ្រួសារ ប្រព័ន្ធសាលារៀន សហគមន៍សាសនា ជាដើម) របស់កុមារ អំពីវិធីដែលបុរសត្រូវសំរបខ្លួននៅក្នុងសង្គម និង ថាតើបញ្ហានេះអាចរួមចំណែក និង អាចជួយដោះស្រាយ បញ្ហាបានយ៉ាងដូចម្តេចនៅក្នុងសង្គម។ អង្គការមិនមែនរដ្ឋាភិបាលមិនគួរត្រឹមតែផ្តល់នូវព័ត៌មានអំពីច្បាប់ប្រឆាំងអំពើ រំលោភសេពសន្ថវៈដល់បុរស និង កុមារាប៉ុណ្ណោះទេ ប៉ុន្តែគួរបន្តធ្វើឱ្យបានកាន់តែយូរ និង ស៊ីជម្រៅនូវការតម្រង់ទិស ឆ្លុះបញ្ចាំង និង ពិនិត្យលើអាកប្បកិរិយារបស់ពួកគេចំពោះស្ត្រី និងក្មេង។ ស្ត្រីត្រូវការព័ត៌មានអំពីច្បាប់ និង ទីកន្លែងដែល ត្រូវទៅនៅពេលដែលពួកគេត្រូវបានគេរំលោភ។ ពួកគេត្រូវការយល់នូវសារសំខាន់នៃការរាយការណ៍ និង ថាការរំលោភ សេពសន្ថវៈ គឺជាការរំលោភសិទ្ធិមនុស្ស និង ជាបទឧក្រិដ្ឋមួយ ហើយមិនមែនជាកំហុសរបស់ពួកគេនោះទេ។ ស្ត្រីគួរតែ ត្រូវបានលើកទឹកចិត្តឱ្យធ្វើដូចនេះ ពួកគេគួរត្រូវបានទទួលនូវបណ្តាញគាំទ្រក្នុងសហគមន៍ ដែលរួមមានទាំងរដ្ឋាភិបាល និង អង្គការ មិនមែនរដ្ឋាភិបាលផងដែរ ។ល។

លើសពីនេះទៀតកម្មវិធីអន្តរាគមន៍ត្រូវតែដោះស្រាយផងដែរ ថាតើមានករណីរំលោភសេពសន្ថវៈចំនួនច្រើនប៉ុណ្ណាបាន កើតឡើងនៅក្នុងរង្វង់សាច់ញាតិគ្រួសារ និង ធានាឱ្យបានថាបញ្ហានេះមិនស្ថិតតែនៅក្នុងរង្វង់គ្រួសារ ប៉ុន្តែត្រូវបានរាយ ការណ៍មកដល់អាជ្ញាធរមានសមត្ថកិច្ច។

មន្ត្រីរដ្ឋាភិបាលស៊ីវិល និង យោធាត្រូវបានរកឃើញថាមានពាក់ព័ន្ធនឹងករណីរំលោភសេពសន្ថវៈ និង ការជួញដូរខ្លះគួរតែ ត្រូវបានដាក់ពិន័យអោយធ្ងន់ធ្ងរសម្រាប់ការដែលមិនត្រឹមតែរំលោភច្បាប់ទេ ថែមទាំងខុសសន្យារបស់ពួកគេដែលជា មន្ត្រីសាធារណៈ និង ជាអ្នកការពារប្រជាជនទៀតផង។ ច្បាប់ក្រមសីលធម៌របស់បុគ្គលិករដ្ឋាភិបាល ទាំងជនស៊ីវិល និង

ជនពាក់ឯកសណ្ឋានគប្បីត្រូវបានចងក្រង ដោយនឹងបង្គាប់ពួកគេអោយសង្កេតពីគ្រប់ច្បាប់ទាំងអស់ដែលមាននៅក្នុងប្រទេស រួមទាំងច្បាប់ ការពារកុមារផងដែរ។ ករណីមួយផ្សេងទៀតដែលបានទាក់ទាញជាពិសេសនោះគឺមានបទល្មើសដ៏ច្រើនប្រឆាំងនឹងកុមារ។ ជនល្មើសទាំងនេះគួរត្រូវបានដាក់ទោសឱ្យធ្ងន់ធ្ងរ។

នៅក្នុងបរិបទនៃភាពក្រីក្រ និង ការអភិវឌ្ឍមិនស្មើគ្នានៅក្នុងប្រទេស វាត្រូវបានគេរំពឹងថាការផ្លាស់ទីទីកន្លែងទាំងនៅក្នុងប្រទេស និងឆ្លងព្រំដែននឹងនៅតែបន្ត ទោះជាវាមិនកើនឡើងក៏ដោយ។ ទោះបីជាកិច្ចខិតខំប្រឹងប្រែងត្រូវបាន ធ្វើដើម្បីដោះស្រាយនូវបញ្ហាឫសគល់ទាំងអស់របស់ជនរងគ្រោះក៏ដោយ វានឹងមិនមានប្រសិទ្ធិភាពភ្លាមៗនោះទេ ដូចនេះវាមានការចាំបាច់ណាស់ដែលត្រូវរកមធ្យោបាយជួយប្រជាជន ដើម្បីជម្នះភាពក្រីក្រ និង ផលលំបាកដែល ធ្វើឱ្យកុមារងាយរងគ្រោះទៅនឹងការរំលោភ និង កេងប្រវ័ញ្ចផ្លូវភេទ។ មានតម្រូវការ ក្នុងការពង្រឹងនូវការផ្សព្វផ្សាយព័ត៌មានប្រឆាំងការជួញដូរ និង រំលោភផ្លូវភេទ និង កេងប្រវ័ញ្ចក្នុងចំណោមអ្នកផ្លាស់ទី ខ្លួនឯងផ្ទាល់ និង ក្រុមគ្រួសាររបស់ពួកគេជាពិសេស អំពីសិទ្ធិរបស់ពួកគេ និង ពីស្ថាប័នទាំងឡាយដែលពួកគេ អាចស្វែងរកជំនួយបាន។ សកម្មភាពនេះគួរតែត្រូវបានធ្វើក្នុងតំបន់បញ្ជូន និង តំបន់គោលដៅដែលបានរកឃើញ។

## V ~ កង្វះខាតទិន្នន័យ

បន្ថែមលើអនុសាសន៍ខាងលើ មានវិធីខ្លះៗផងដែរដែលអាចជួយកែលំអ និង ធ្វើឱ្យប្រសើរឡើងនូវការសិក្សាស្រាវជ្រាវដើម្បីធ្វើឱ្យវាកាន់តែមានសារសំខាន់ឡើងសម្រាប់ការអភិវឌ្ឍន៍កម្មវិធីក្នុងការដោះស្រាយបញ្ហានេះ។

ការទាមទារថាមានកំណើនកើនឡើងនូវអំពើជួញដូរ និង រំលោភសេពសន្ថវៈត្រូវបានគេយកមកធ្វើជាមូលដ្ឋានដើម្បីបង្កើតកម្មវិធី និងស្នើសុំមូលនិធិ ដែលរហូតមកដល់ពេលនេះនៅពុំទាន់ស្ថិតិច្បាស់លាស់ដើម្បីបញ្ជាក់ឡើយ។ ដូចនេះវាមានសារសំខាន់ណាស់ក្នុងការចងក្រងឯកសារច្បាស់លាស់ និងរួមគ្នា ដើម្បីអាចកំណត់បញ្ហានេះ ដោយរួមគ្នាពិនិត្យ និងកំណត់នូវព័ត៌មានដែលចាំបាច់ និង វិធីសាស្ត្រក្នុងការប្រមូលទិន្នន័យឱ្យបានច្រើនតាមតែអាចធ្វើបាន ដើម្បីវិភាគព័ត៌មានឱ្យបានច្បាស់លាស់ និង ប្រៀបធៀបនិន្នាការនៅពេលអនាគត និង តាមទីកន្លែងខុសៗគ្នា។ នេះវាមិនត្រឹមតែត្រូវការភាពជាដៃគូទៅវិញទៅមករវាងអ៊ិកផាត និង អង្គការដែលចូលរួមប៉ុណ្ណោះទេ ប៉ុន្តែគឺយន្តការសម្របសម្រួលដែលនឹងអនុញ្ញាតឱ្យមានការផ្លាស់ប្តូរច្រើន និង ភ្លាមៗរវាង និង ក្នុងចំណោមអង្គការដែលចូលរួម។

អង្គការមិនមែនរដ្ឋាភិបាលនានាមានអាណត្តិរៀងៗខ្លួន (ឧទាហរណ៍ : មណ្ឌល សេវាផ្លូវច្បាប់ សុខភាព) ហេតុដូចនេះហើយមានការរក្សាទុកកំណត់ត្រា ឬ របៀបធ្វើឯកសារផ្សេងគ្នារៀងៗខ្លួន ប៉ុន្តែពួកគេចាំបាច់ ត្រូវធ្វើការជាមួយគ្នាដើម្បីជួយបង្កើតនូវរូបភាពពេញលេញ និង ច្បាស់លាស់ជាងមុន អំពីបញ្ហាដ៏ស្មុគ្រស្មាញដូចជា ការរំលោភសេពសន្ថវៈ និង ជួញដូរ ដើម្បីមានមូលដ្ឋានកាន់តែច្បាស់លាស់ និង ទូលំទូលាយ សម្រាប់ ការតស៊ូមតិលើគោល នយោបាយ និងការអភិវឌ្ឍន៍កម្មវិធី។

ខណៈដែលអំពើរំលោភ និង ជួញដូរត្រូវបានរាយការណ៍នៅទូទាំងប្រទេស ប៉ុន្តែនៅកន្លែងខ្លះត្រូវបាន រាយការណ៍ច្រើនជាងនៅទីកន្លែងផ្សេងទៀត។ លក្ខខណ្ឌនៅក្នុងទីកន្លែងទាំងនេះចាំបាច់ត្រូវការស៊ើបអង្កេតបន្ថែមទៀត មានន័យថាប្រសិនបើឧប្បត្តិហេតុនៃ អំពើរំលោភនោះមានច្រើនពិតនៅទីកន្លែងនោះ ឬ គ្រាន់តែមាន ក្នុងរបាយការណ៍។ តើមានកត្តាអ្វីខ្លះ ដែលរួមចំណែកទៅក្នុងករណីនិមួយៗ? ការសិក្សាស្រាវជ្រាវបន្តដែលកាន់តែ ស៊ីជម្រៅគួរតែត្រូវបានគេអនុវត្តដើម្បីព្យាយាមឆ្លើយតបនឹងសំណួរទាំងនេះ ធ្វើដូចនេះវិធានការមានប្រយោជន៍ អាចត្រូវបានរកឃើញ ដើម្បីដោះស្រាយបញ្ហានេះ។

ព័ត៌មានស្តីពីសេវាកម្មផ្សេងៗចាំបាច់ត្រូវប្រមូល វិភាគ និង ចែកចាយផងដែរ។ ជាទូទៅមានតម្រូវការជាចាំបាច់ក្នុងការដាក់បញ្ចូលគ្នានូវព័ត៌មានពេញលេញ និង ច្បាស់លាស់ស្តីពីសេវាកម្មផ្សេងៗដែលផ្តល់ដោយអង្គការ ដើម្បីកំណត់បាននូវលទ្ធផល និង រកមធ្យោបាយក្នុងការសម្របសម្រួលកិច្ចខិតខំប្រឹងប្រែង និង បង្កើនធនធាន ឱ្យដល់កម្រិតអតិបរមា។ ច្បាស់ជាងនេះទៅទៀតមានតម្រូវការចាំបាច់ក្នុងការរកឱ្យឃើញ និង កំណត់ឱ្យបានច្បាស់លាស់នូវព័ត៌មានចាំបាច់នៅតាមតំបន់ផ្សេងៗ ថាតើប្រព័ន្ធយុត្តិធម៌ដោះស្រាយយ៉ាងដូចម្តេចជាមួយការរំលោភសេព សន្ថវៈ និង ជួញដូរលើកុមារ ដោយរួមបញ្ចូលទាំងផលវិបាកផ្លូវចិត្តនិងសង្គមនៃអំពើរំលោភសេពសន្ថវៈ និង ជួញដូរ និងបញ្ហានេះត្រូវដោះស្រាយយ៉ាងដូចម្តេច។

ខណៈដែលកម្មវិធីរបស់ អ៊ិកផាត ផ្តោតលើពេស្យាចារ និង ការជួញដូរផ្លូវភេទ វាមានសារសំខាន់ផងដែរក្នុងការតាមដានលើទម្រង់ផ្សេងៗទៀត ឬ គោលបំណងរបស់ការជួញដូរ ដើម្បីកំណត់ឱ្យបាននូវតម្រូវការ របស់ជនរងគ្រោះដទៃទៀត និង ដើម្បីកំណត់ថាតើទម្រង់ទាំងនោះប្រទាក់គ្នាជាមួយការរំលោភ និង ជួញដូរផ្លូវភេទ យ៉ាងដូចម្តេច។

ប្រទេសកម្ពុជានៅពេលនេះមានកិច្ចព្រមព្រៀងជាមួយប្រទេសថៃ និង វៀតណាមស្តីពីបញ្ហាជួញដូរ។ ដោយសារកិច្ចព្រមព្រៀងនេះនៅថ្មី វាចាំបាច់ និង មានសារសំខាន់ណាស់ក្នុងការដឹងថាតើខ្លឹមសារនៃកិច្ចព្រមព្រៀងនេះ ត្រូវបានគេអនុវត្ត ឬទេ ឬក៏បញ្ញត្តិទាំងឡាយគ្រប់គ្រាន់សមស្របឬទេ។ ទោះបីជាការសង្កេត ឬឯកសារអ្វីក៏ដោយរបស់ ករណីជាក់លាក់ដែលបានធ្វើ គួរតែដាក់ចូលទៅក្នុងការត្រួតពិនិត្យឡើងវិញនូវកិច្ចព្រមព្រៀងនេះ នាពេលអនាគត។

## ឯកសារយោង


១. អង្គការបំបាត់ពេស្យាចារកុមារ រូបភាពអាសអាភាស និងជួញដូរកុមារដើម្បីគោលបំណងផ្លូវភេទ (អ៊ិកផាត អន្តរជាតិ) របាយការណ៍តាមដានត្រួតពិនិត្យ អំពីស្ថានភាពសកម្មភាពប្រឆាំង នឹងការធ្វើអាជីវកម្ម កេងប្រវ័ញ្ចផ្លូវភេទលើកុមារ កម្ពុជា ឆ្នាំ២០០៦

២. គម្រោងស្នើសុំរបស់អ៊ិកផាតទៅANESVAD ស្តីអំពីស្ថិតិរួមរបស់អង្គការនានាស្តីអំពីការរំលោភ និង ជួញដូរ ខែកញ្ញា ឆ្នាំ ២០០៥

៣. ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ ច្បាប់ចុងក្រោយ របស់រាជរដ្ឋាភិបាលកម្ពុជា ២៧ មករា ២០០៦

៤. ការពិនិត្យឡើងវិញនូវការស្រាវជ្រាវរយៈពេលមួយទសវត្សស្តីពីការជួញដូរមនុស្ស របស់មូលនិធិអាស៊ី និង មជ្ឈមណ្ឌលសម្រាប់ការសិក្សាជាន់ខ្ពស់ ដោយ Annuska Derks, Roger Henke និង លី វណ្ណា ខែឧសភា ឆ្នាំ២០០៦

៥. វិទ្យាស្ថានជាតិស្ថិតិ/ក្រសួងផែនការ ឆ្នាំ២០០៤ ការស្ទាបស្ទង់ពីសេដ្ឋកិច្ចសង្គម ភ្នំពេញ: NIS/MoP

៦. វិទ្យាស្ថានជាតិស្ថិតិ/ក្រសួងផែនការ ការស្ទាបស្ទង់ពី ភូមិសាស្ត្រកម្ពុជានិងសុខភាព ឆ្នាំ២០០០

៧. វិទ្យាស្ថានជាតិស្ថិតិ/ក្រសួងផែនការ សៀវភៅស្ថិតិប្រចាំឆ្នាំ ២០០៥

៨. របាយការលទ្ធផលរបស់គម្រោងរបស់ CWCC ស្តីពីការជួយស្ត្រីមានវិបត្តិនៅខេត្តបន្ទាយមានជ័យ ខែកក្កដា ដល់ខែធ្នូ ឆ្នាំ២០០៥

៩. UNIFEM, WB, ABD, UNDP និង DFID/UK 2004 ចំណែកយុត្តិធម៌សម្រាប់ស្ត្រី: ការវាយតំលៃបញ្ហា យ៉េនឌ័រកម្ពុជា។ UNIFEM, WB, ABD, UNDP និង DFID/UK ភ្នំពេញ។

១០. របាយការណ៍សិទ្ធមនុស្ស របស់ អាដហុក ឆ្នាំ២០០៤

១១. របាយការណ៍របស់លីកាដូ ឆ្នាំ២០០៦ ស្តីពីអំពើហិង្សាប្រឆាំងស្ត្រីក្នុងឆ្នាំ២០០៥

១២. កាសែតឌឹខេមបូឌាដេលី, ថ្ងៃទី៨ មករា ឆ្នាំ២០០៧ "កុមាររងគ្រោះអាយុ១២ឆ្នាំ ខ្លាចមិនហាននិយាយជាមួយ នគរបាល, អង្គការ" ដោយ Chhay Channyda

១៣. ក្រសួងកិច្ចការនារី, កិច្ចការនារីក្នុងឯកសារច្បាប់ ឧបត្ថម្ភដោយ គម្រោង GTZ ស្តីពីការលើកកំពស់សិទ្ធិស្ត្រី

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ១. លក្ខខណ្ឌយោង

## គណៈកម្មាធិការបំបាត់ពេស្យាចារ ការរំលោភ និងជួញដូរកុមារនៅកម្ពុជា (អ៊ិកផាត កម្ពុជា)
## "ការវិភាគទិន្នន័យនិងសរសេររបាយការណ៍"
## ខែធ្នូ ឆ្នាំ២០០៦

## លក្ខខណ្ឌយោង

### ១. សាវតា

**អ៊ិកផាត**

អ៊ិកផាត កម្ពុជាត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៥ ដោយអង្គការមួយក្រុមដែលធ្វើការដើម្បីលុបបំបាត់ការរំលោភ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។ អ៊ិកផាតបានក្លាយជាសមាជិករបស់អ៊ិកផាត អន្តរជាតិ នៅខែកញ្ញា ឆ្នាំ២០០២។ អង្គការនេះមានបំណងប្រមូលផ្តុំអ្នកពាក់ព័ន្ធសំខាន់ៗទាំងអស់ និង លើកកម្ពស់ការសម្របសម្រួលសកម្មភាព ដើម្បីលុបបំបាត់ពេស្យាចារកុមារ រូបភាពអាសអាភាសកុមារ និងការជួញដូរកុមារក្នុងគោលបំណងផ្លូវភេទ។ អ៊ិកផាត កម្ពុជាជាបណ្តាញមួយដែលមានសមាជិកជាអង្គការជាតិ និង អន្តរជាតិចំនួន២៦ ធ្វើការរួមគ្នាដើម្បីធានាថាកុមារទាំងអស់នៅក្នុងប្រទេសទទួលបានសិទ្ធិជាមូលដ្ឋានរបស់ពួកគេ ចាកផុតពីគ្រប់ទម្រង់នៃការរំលោភបំពាននិងកេងប្រវ័ញ្ចផ្លូវភេទ។

ទស្សនៈវិស័យរបស់អ៊ិកផាតគឺ : ធ្វើឱ្យក្លាយជាការពិតនូវសិទ្ធិរបស់កុមារទាំងអស់ដើម្បីរស់នៅដោយជៀសផុតពី ពេស្យាកុមារ ការរំលោភ រូបភាពអាសអាភាស និងការជួញដូរកុមារក្នុងគោលបំណងផ្លូវភេទ។ បេសកកម្មរបស់ អង្គការនេះគឺធ្វើឱ្យទស្សនៈរបស់ខ្លួនក្លាយជាការពិតតាមរយៈ ការលើកកម្ពស់ការយល់ដឹង តស៊ូមតិ ការត្រួតពិនិត្យតាមដាន និងការសម្របសម្រួលសកម្មភាព និងព័ត៌មានក្នុងចំណោមអ្នកពាក់ព័ន្ធ។

ដើម្បីស្វែងយល់ពីមូលហេតុ ឫសគល់របស់ការរំលោភ និងជួញដូរដែលមានដំណើរការស្មុគស្មាញ និងភាព ស្ទាត់ជំនាញ អ៊ិកផាតបានចាប់ផ្តើម គម្រោងមួយដែលអាចធ្វើជាមគ្គុទេសក៏សម្រាប់អង្គការនានាក្នុងការកំណត់ តំបន់អាទិភាពដែលអាចធ្វើឱ្យធនធាន និង ជំនួយរបស់ពួកគេត្រូវបានតភ្ជាប់ និង ប្រើប្រាស់ដោយមានប្រសិទ្ធិភាព។

គម្រោងផ្តល់នូវការវិភាគស្ថិតិដែលមានសុពលភាព និង ភាពជឿជាក់បាននៃករណីរំលោភ និង ជួញដូរដែលបានរាយការណ៍នៅឆ្នាំ២០០៣-២០០៤ ដើម្បីបង្កើតនូវព័ត៌មានជាគ្រឹះសំខាន់សម្រាប់អង្គការនានា និង គម្រោងអនាគតរបស់ពួកគេ។ គម្រោងមានបំណងរៀបរៀង និង សម្របសម្រួលកំណត់ត្រារបស់អង្គការនានា ដើម្បីធានា ការរាយការណ៍ និងចែករំលែកព័ត៌មានជាមូលដ្ឋាន និងពង្រឹងកិច្ចសហការរវាងអង្គការដែលធ្វើការដើម្បីទប់ស្កាត់ និងជួយជនរងគ្រោះក្នុងករណីរំលោភនិងជួញដូរ។

គម្រោងបានប្រមូល និង រៀបរៀងទិន្នន័យ និង ព័ត៌មានស្តីពីការរំលោភ និង ជួញដូរកុមារាកុមារីគ្រប់អាយុ និង ជនជាតិនៅប្រទេសកម្ពុជាក្នុងឆ្នាំ២០០៣ ដល់ ឆ្នាំ២០០៤។ ព័ត៌មានត្រូវបានប្រមូលពីបណ្តាអង្គការដែលចូលរួម ដោយជ្រើសរើស

ការងាររបស់ពួកគេនៅក្នុងតំបន់។ ទិន្នន័យដែលប្រមូលបានត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យ ដែលបង្កើតឡើងសម្រាប់គោលបំណងនេះ។ ជាមួយទិន្នន័យដែលបានបញ្ចូល អ៊ិកផាត ឥឡូវនេះកំពុងតែស្វែងរកអ្នកផ្តល់យោបល់ដើម្បីធ្វើការវិភាគទិន្នន័យ និងសរសេររបាយការណ៍ស្តីពីទិន្នន័យដែលបានប្រមូល។

## ២. ការវិភាគទិន្នន័យ និង ការសរសេររបាយការណ៍

លទ្ធផលនៃការពិគ្រោះយោបល់នឹងធ្វើជារបាយការណ៍ចុងក្រោយសម្រាប់គម្រោងប្រព័ន្ធទិន្នន័យ ដែលនឹងត្រូវចែករំលែកដល់អ្នកពាក់ព័ន្ធទាំងឡាយ និង ភាគីពាក់ព័ន្ធផ្សេងទៀតនៅដើមឆ្នាំ២០០៧។ វានឹងផ្តល់ឱ្យអ៊ិកផាត នូវឱកាសរក្សាទុកទិន្នន័យដែលបានប្រមូលមកទល់នឹងពេលនេះ និង ធ្វើផែនការដើម្បីពិនិត្យឡើងវិញ/ឬបន្តគម្រោង នេះទៅពេលអនាគត។

គោលបំណងចម្បងនៃការពិគ្រោះយោបល់នេះគឺដើម្បីវិភាគ និង បង្កើតជារបាយការណ៍មួយស្តីអំពីការរំលោភ និង ជួញដូរនៅប្រទេសកម្ពុជា ដោយផ្អែកលើព័ត៌មានដែលផ្ទុកនៅក្នុងប្រព័ន្ធទិន្នន័យរបស់អ៊ិកផាតដែលបានទាញយក ការឆ្លើយតបពីតារាងសំណួរដែលបង្កើតដោយអ៊ិកផាត និង ទម្រង់ផ្សេងៗដែលផ្តល់ដោយអង្គការដៃគូនានា។ លទ្ធផលរបស់របាយការណ៍នឹងមានជាពីរផ្នែកគឺមួយអំពីការរំលោភ និង មួយទៀតអំពីការជួញដូរ។

## ៣. ទំហំការងារ

គោលបំណងសំខាន់នៃការពិគ្រោះយោបល់គឺដើម្បីវិភាគទិន្នន័យពីប្រព័ន្ធទិន្នន័យរបស់អ៊ិកផាត និង ដើម្បីកំណត់ភាពខ្សោយ និងការខ្វះខាតនៅក្នុងប្រព័ន្ធ។

ជាងនេះទៀតការពិគ្រោះយោបល់នឹងផ្តល់ផងដែរនូវអនុសាសន៍ដល់អ៊ិកផាត កម្ពុជា ថាតើប្រព័ន្ធទិន្នន័យអាចនឹងកែសំរួលអោយកាន់តែប្រសើរឡើងដោយរបៀបណានាពេលអនាគត។

ការវិភាគ និង របាយការណ៍ត្រូវគ្របដណ្តប់លើទិន្នន័យ និង ព័ត៌មានដែលរកឃើញនៅក្នុងប្រព័ន្ធទិន្នន័យប្រសិនបើមាន និង អាចផ្តោតលើបញ្ហាសំខាន់ និង ពាក់ព័ន្ធជាងគេទៅក្នុងការរំលោភ និង ជួញដូរ។

នៅចុងបញ្ចប់នៃបេសកកម្មអ្នកផ្តល់យោបល់នឹងដាក់/បញ្ជូនរបាយការណ៍ជូនអ៊ិកផាត កម្ពុជា។

## ៤. អ្នកផ្តល់យោបល់ និង តារាងពេលវេលា

អ្នកផ្តល់យោបល់ឯករាជ្យនឹងត្រូវចុះកិច្ចសន្យា និង ផ្តល់ហិរញ្ញវត្ថុដោយអ៊ិកផាត។ អ្នកផ្តល់យោបល់ទទួលខុសត្រូវលើការវិភាគទិន្នន័យពីប្រព័ន្ធទិន្នន័យរបស់អ៊ិកផាត ការសរសេរ និង ដាក់ជូនរបាយការណ៍ជាលក្ខណៈឯកសារអេឡិចត្រូនិក។

ការងារនឹងត្រូវអនុវត្តក្នុងរយៈពេល១៤ថ្ងៃ ដែលប្រមាណជា៧ថ្ងៃនឹងត្រូវធ្វើនៅការិយាល័យរបស់អ៊ិកផាត នៅភ្នំពេញ ជាកន្លែងដែលទិន្នន័យទាំងអស់ដែលត្រូវការនឹងត្រូវយកចេញពីប្រព័ន្ធទិន្នន័យ។ ការពិគ្រោះយោបល់នេះ មិនបូកបញ្ចូលការងារចុះតាមភូមិទេ ហើយអាស្រ័យលើប្រព័ន្ធទិន្នន័យដែលមានស្រាប់របស់អ៊ិកផាតទាំងស្រុង។ អ្នកផ្តល់យោបល់នឹងត្រូវចាប់ផ្តើមការងារនៅថ្ងៃទី ០៧ ខែធ្នូ ឆ្នាំ២០០៦ និងផ្តល់របាយការណ៍តាមអ៊ីម៉េលនៅថ្ងៃ ទី២២ខែធ្នូ ឆ្នាំ២០០៦។

**កាលវិភាគ**

